មជ្ឈមណ្ឌលឯកសារកម្ពុជា

# សម្ភាសជាមួយឈ្មោះ ជូ លន់ ភេទប្រុស កើតថ្ងៃទី១ ខែមករា ឆ្នាំ១៩៥៧

## មុខងារជំនាន់ខ្មែរក្រហមៈ "យោធា"

## សព្វថ្ងៃនៅភូមិអូរគគីរកណ្ដាល ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

## ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ ផាត កុសល

## ០១:៣៦:២៣

## ៤២ទំព័រ

កុសលៈ ភូមិនេះភូមិអីដែលបង?

លន់ៈ ភូមិនេះភូមិអូរគគីរកណ្ដាល ។

កុសលៈ ចឹងភូមិអូរគគីរកណ្ដាលចឹងបង?

លន់ៈ បាទ ។

កុសលៈ ឃុំ?

លន់ៈ ឃុំលំទង ។

កុសលៈ ស្រុក?

លន់ៈ អន្លង់វែង ខេត្តឧត្តរមានជ័យ ។

កុសលៈ ថ្ងៃនេះថ្ងៃប៉ុន្មានចេះ ថ្ងៃ២៣?

លន់ៈ ថ្ងៃ២៣ ។

កុសលៈ ២៣ឬ២៤?

លន់ៈ ២៤ ។

កុសលៈ ចឹង២៤?

លន់ៈ បាទ ។

កុសលៈ ខ្ញុំឈ្មោះ ផាត កុសល អ្នកបកប្រែអត់មានទេ ចឹងគោលបំណងនៃការស្ទាបស្ទង់មតិនេះ ដើម្បីយកទៅសម្រាប់ការអប់រំមួយមុខតែប៉ុណ្ណោះបង អត់មានយកទៅធ្វើអីទេ យើងខ្ញុំ ទាក់ទងទៅនិងសាកលវិទ្យាល័យភ្នំពេញ តែការបទសម្ភាសនេះមិនអាចយកទៅឲ្យអ្នកណា ប្រើប្រាស់ទេ ខ្វាចខូចត្រកូលគេណាបង ។

លន់ៈ បាទ ។

កុសលៈ បាទ!គឺយកទៅបម្រើក្នុងការអប់រំមួយគត់ បងឈ្មោះ អីដែលបង?

លន់ៈ ថូ លន់ ។

កុសលៈ ឥឡូវនេះជាប្រធានភូមិបង?

លន់ៈ បាទ ។

កុសលៈ ថ្ងៃខែឆ្នាំកំណើតបងមានចាំទេ?

លន់ៈ ថ្ងៃទី១ ខែ១ ។

កុសលៈ ថ្ងៃទី១ ខែ១ល្អណាស់ ឆ្នាំ?

លន់ៈ ឆ្នាំ៥៧ ។

កុសលៈ បងឪពុកខ្ញុំ៥ឆ្នាំ ចឹងទីកន្លែងភូមិកំណើត?

លន់ៈ ភូមិដូរបក្រី ។

កុសលៈ ឃុំ?

លន់ៈ ឃុំត្រីញ័រ ។

កុសលៈ ស្រុក?

លន់ៈ ស្រុកពួក ។

កុសលៈ ខេត្តសៀមរាប?

លន់ៈ បាទ ។

កុសលៈ អ្នកសៀមរាបដូចគ្នាសោះហ្នឹងណាស់ អាស័យដ្ឋានបច្ចុប្បន្នដូចខាងលើ?

លន់ៈ បាទ ។

កុសលៈ ចឹងសូមបងរៀបរាប់កាលពីជំនាន់រំដោះនិយាយពីជីវប្រវត្តិរបស់បងពីឆ្នាំ៧៣ ពីឆ្នាំ៧០ រហូតមកមុនរដ្ឋប្រហារហ្នឹងគឺថា សភាពបងឪពុកម្ដាយបងនៅក្នុងសភាពពេលហ្នឹងយ៉ាងម៉េចដែរ រហូតមកដល់ពេលចូលបដិវត្ត?

លន់ៈ ខ្ញុំវាកើតក្នុងត្រកូលអ្នកក្រ ។

កុសលៈ បាទ ។

លន់ៈ ដល់ចឹងទៅបើនិយាយពីការសិក្សារៀនសូត្រជាជីវិតរបស់ខ្ញុំគឺអត់មានទេ នៅឆ្នាំ៧៣ខ្ញុំចេញពីផ្ទះនៅក្នុងអំឡុងឆ្នាំ៧០ណាស់ ។

កុសលៈ ខ្ញុំកាត់ប្រសាសន៍បងបន្តិច កាលហ្នឹងសមាជិកគ្រួសារបងទាំងអស់មានប៉ុន្មាននាក់បង?

លន់ៈ សមាជិកគ្រួសារខ្ញុំនេះវាមានសមាជិកគ្នាច្រើនដែលប៉ុន្មានចេះ មើលមាន៧នាក់ ។

កុសលៈ ចឹងមាន៧នាក់ បាទសូមតទៀតបង ចឹងកាលនោះមិនទាន់ការទេ មិនទាន់មានគ្រួសារនៅឡើយទេ?

លន់ៈ ខ្ញុំនៅអាយុ១៣ឆ្នាំនៅឡើយតើ ។

កុសលៈ បាទ!កូនកសិករក្រ សូមរៀបរាប់តបាទ ។

លន់ៈ ដល់ឆ្នាំ៧៣-៧៤-៧៥ យើងត្រូវរំដោះសម័យនោះណាស់ ។

កុសលៈ បាទ ។

លន់ៈ ខ្ញុំនៅជាប់ជួរកងទ័ព ៧៥គេឲ្យខ្ញុំមកនៅឧត្ដរមានជ័យ ដល់សម័យនោះក៏ខ្ញុំនៅជាជួរកងទ័ពដែរ ។

កុសលៈ បាទ ។

លន់ៈ រហូតដល់៧៩ ដល់ថ្ងៃ៧មករា ។

កុសលៈ បាទ ។

លន់ៈ ខ្ញុំក៏នៅតែខាងខ្មែរក្រហមហ្នឹងឯង ។

កុសលៈ កាលហ្នឹងបងចូលទ័ពអាយុប៉ុន្មានបង?

លន់ៈ អាយុ១៣ឆ្នាំ ។

កុសលៈ ចឹងតាំងពីអាយុ១៣ឆ្នាំមក?

លន់ៈ បាទ ។

កុសលៈ ចូលនៅស្រុកពួកយើងហ្នឹង?

លន់ៈ នៅពួកយើងហ្នឹង ។

កុសលៈ ពេលហ្នឹងគេប្រាប់យើងថា ម៉េចខ្លះ មូលហេតុដែលយើងចូលពេលហ្នឹង គេប្រាប់យើងថាម៉េចខ្លះ វ៉ៃអាមេរិចកាំង?

លន់ៈ ទេ កាលនោះគេនិយាយពីរឿងវ៉ៃចក្រព័ត្តសក្តិភូមិនាយទន់លន់ នល់ នយោបាយរបស់គេនោះណាស់ គេអប់រំណែនាំតែចឹង ហ្នឹងជាគោលការណ៍របស់គេ ។

កុសលៈ ចឹងគោលការណ៍ជារួមគេនិយាយប្រាប់ថាវ៉ៃពួកលន់ នល់?

លន់ៈ វ៉ៃពួកលន់ នល់ ។

កុសលៈ អត់មានទាក់ទងដល់សម្ដេចទេ ពេលហ្នឹង?

លន់ៈ ដូចជាមិនមានទេ ។

កុសលៈ ចឹងកាលហ្នឹងសម្ដេចអត់មានអមពាវនាវឲ្យចូលព្រៃទេ?

លន់ៈ បាទ!អំពាវនាវឲ្យចូលព្រៃម៉ាគឺ ។

កុសលៈ ចឹងកាលសម្រេចចិត្តរបស់បងពេលហ្នឹងដូចថាយើងចូលទ័ពរំដោះហ្នឹង យើងដូចថាដើម្បីផ្តួលរំលំរបបលន់ នល់បងណែស?

លន់ៈ បាទ ។

កុសលៈ ផ្តួលរលំពួកលន់ នល់ ពួករលួយចក្រព័ត្តអាមេរិចកាំងចឹង?

លន់ៈ បាទ ។

កុសលៈ មានមូលហេតុអីទៀតទេ សម្តេចអត់ទេ សម្តេចឪអត់មានពាក់ព័ន្ធទេ?

លន់ៈ ដូចជាមិនមានពាក់ព័ន្ធ ដូចថាតាមរយៈហ្នឹងទៅបានយើងរត់ចូលព្រៃណាស់ ។

កុសលៈ បាទ ។

លន់ៈ ចូលតាមការអំពាវនាវហ្នឹងហើយ ។

កុសលៈ ចឹងបងយល់ថា របបពួកលន់ នល់ ពេលហ្នឹងយ៉ាងម៉េចដែរ ពុករលួយអយុត្តិធម៌ឬមួយយ៉ាងម៉េច?

លន់ៈ ដោយខ្ញុំនេះនៅក្មេងពេក គ្មានការសិក្សាគ្មានការអប់រំនៅក្មេងណាស់ ។

កុសលៈ បាទ ។

លន់ៈ នេះម៉្យាងហើយម៉្យាងទៀតភូមិសាស្ត្ររបស់ខ្ញុំនេះស្ថិតនៅជាមួយពួកខ្មែរក្រហមកាន់កាប់ទៅហើយ ហើយមិនសូវយល់ ។

កុសលៈ ចឹងមិនសូវយល់ពេលហ្នឹង?

លន់ៈ បាទ ។

កុសលៈ ចឹងគេប្រាប់ឃោសនាចឹងយើងចូល?

លន់ៈ យើងនៅក្មេងចេះតែចូលគេទៅ ។

កុសលៈ ចឹងសូមបងរៀបរាប់បន្តទៀតចឹង ឆាកជីវិតរបស់បងពេលហ្នឹងយ៉ាងម៉េចដែរពេលហ្នឹងបន្ទាប់ពីរបបខ្មែរក្រហមគេឲ្យទៅធ្វើទាហាន?

លន់ៈ បាទ!ឲ្យធ្វើទាហានដល់ឆ្នាំ៧៥ហើយណាស់ ដល់ឆ្នាំ៧៥គេជម្លៀសខ្ញុំឲ្យមកនៅខេត្តរមានជ័យហ្នឹង ។

កុសលៈ តំបន់នេះឯង?

លន់ៈ បាទ!នៅស្រុកសំរោងបីឆ្នាំ ។

កុសលៈ ហើយយ៉ាងម៉េចទៀតទៅបងនៅពេលហ្នឹង?

លន់ៈ នៅពេលហ្នឹងខ្ញុំធ្វើយោធាដដែលហ្នឹង នៅជាជួរកងទ័ពដដែលណាស់ សកម្មភាពរបស់ខ្ញុំជាតួនាទីគេឲ្យខ្ញុំទទួលខុសត្រូវដោយឡែក ឲ្យយាមតែផ្លូវ ។

កុសលៈ ចឹងតួនាទីយាមផ្លូវ?

លន់ៈ បាទ ។

កុសលៈ ចឹងយោធាយោធិនតួនាទីយាមផ្លូវហ្នឹងបង?

លន់ៈ បាទ ។

កុសលៈ យាមផ្លូវខាងណាខ្លះបង?

លន់ៈ យាមផ្លូវយើងផ្លូវលេខ៦៨ហ្នឹង ពីក្រឡាញ់មកសំរោងណាស់ ខ្ញុំយាមកន្លែងភូមិដូនកែន ហ្នឹងមានវត្តមួយនៅហ្នឹង ។

កុសលៈ បាទ ។

លន់ៈ យាមនៅហ្នឹងពីរឆ្នាំ ក្រោយមកបានគេដកខ្ញុំឲ្យមកដាំបន្លែឲ្យគេហូបម្តងមួយឆ្នាំ ។

កុសលៈ ចឹងកាលហ្នឹងនៅក្នុងកងពលអីដែលកាលហ្នឹង?

លន់ៈ កាលនោះខ្ញុំនៅជាកងទ័ពស្រុកទេ ។

កុសលៈ ចឹងកងទ័ពស្រុក?

លន់ៈ បាទ ។

កុសលៈ កងទ័ពស្រុកលេខប៉ុន្មាន?

លន់ៈ គេហៅកងទ័ពស្រុកសំរោងបណ្តោយ ។

កុសលៈ ចឹងកាលហ្នឹងប្រធានស្រុកគាត់ឈ្មោះអីដែរ?

លន់ៈ សម័យខ្ញុំនៅហ្នឹងឈ្មោះ លក់ សារិក ។

កុសលៈ គាត់មកពីខាងណាបង?

លន់ៈ ខាងនោះគេហៅខាងពួកនិរតីនោះណាស់ ។

កុសលៈ ចឹងខាងពួកនិរតី?

លន់ៈ បាទ ។

កុសលៈ ចឹងកាលហ្នឹងនៅក្រោមការគ្រប់គ្រងរបស់តា ម៉ុក មិនមែនទេបង?

លន់ៈ និយាយរួមពួកក្រុមតា ម៉ុកទាំងអស់ហ្នឹង ។

កុសលៈ ចឹងគាត់កាន់រហូតដល់ឆ្នាំ៧៩តែម្តង មេស្រុកហ្នឹង?

លន់ៈ បាទ!អត់ទេ នៅឆ្នាំ៧៧ សកម្មភាពមានក្បត់ពួកគ្នាគេហ្នឹង កាលខ្ញុំនៅទាន់ត្រឹមលោក សារិកណាស់ ។

កុសលៈ បាទ ។

លន់ៈ កាលពីមុនមួយជំនាន់ទៅហើយ ។

កុសលៈ ចឹងកាលចូលហ្នឹង៧៧ទេ?

លន់ៈ បាទ ត្រឹមលោកសារិក ពីមុននោះខ្ញុំមិនបានស្គាល់ទេ ។

កុសលៈ គេចាប់អស់?

លន់ៈ គេចាប់អស់មួយខ្សែទៅ បានលោកសារិកមក លោកសារិកមកចុង៧៧ដើម៧៨ ក៏លោកសារិកហ្នឹងទៅមួយសារទៀត មកលោករុំនោះទៀត ។

កុសលៈ ចឹងគេចាប់ឆ្នាំ៧៨គេចាប់?

លន់ៈ បាទ ។

កុសលៈ ចឹងក្រោយមកលោករុំ?

លន់ៈ បាទ! ។

កុសលៈ លោករុំហ្នឹងនៅរហូតដល់ណាទៅ និរតីដែលអត់ទេ?

លន់ៈ និរតីដូចគ្នាសុទ្ធតែនិរតីទាំងអស់ហ្នឹង ។

កុសលៈ គាត់មកដល់ឆ្នាំ៧៨?

លន់ៈ បាទ ។

កុសលៈ ខែប៉ុន្មានបងមានចាំទេ?

លន់ៈ ដូចជាមកក្នុងអំឡុងខែបីហ្នឹង ។

កុសលៈ ចឹងកាលហ្នឹងគាត់មានដាក់តួនាទីឲ្យមកធ្វើអីផ្សេងទេ កាលហ្នឹង?

លន់ៈ ខ្ញុំមកនៅហ្នឹងមិនដែលបានទទួលតួនាទីអីហ្នឹងគេទេ មកធ្វើតែយុទ្ធធម្មតាហ្នឹង ដល់ហើយចូលដល់ឆ្នាំ៧៩ម្តង ៧៩បានចាប់ផ្តើមគេវៃបែកមកខ្ញុំក៏រត់ទៅ ។

កុសលៈ បាទ ។

លន់ៈ ជាប់ជាមួយអន្តភាពកងទ័ពដូចគ្នា កងចល័តខ្លះ រហូតទៅដល់អំពិល ។

កុសលៈ ចឹងពេលហ្នឹងរត់ទៅតាមគេ ពេលហ្នឹង?

លន់ៈ រត់តាមគេ ។

កុសលៈ ៧៩មក?

លន់ៈ បាទ ។

កុសលៈ ខ្ញុំសូមសួរបងមួយទៀតកាត់ប្រសាសន៍បងបន្តិច ចឹងយើងគិតមើលទៅក្នុងរបបហ្នឹងបង តើបងយល់ខ្លួនឯងហ្នឹងជាជនរងគ្រោះ ជាកម្មាភិបាលឬក៏ថាយើងធ្លាប់ឆ្លងកាត់ទាំងពីរ យើងជាជនរងគ្រោះឬមួយយ៉ាងម៉េច?

លន់៖ គិតទៅយើងសុទ្ធតែជាជនរងគ្រោះដូចតែគ្នា ព្រោះថាក្រោមរបបនៃសង្គម បើគិតឲ្យដល់ទៅសុទ្ធតែជាអ្នករងគ្រោះដូចតែគ្នាទេ ។

កុសល៖ ហេតុអីបានបងយល់ថា ជាជនរងគ្រោះ?

លន់៖ ពីព្រោះថា នៅក្រោមទិដ្ឋិតរបស់គេ នៅក្រោមបញ្ជារបស់គេ ។

កុសល៖ បើគិតទៅពីណាជាអ្នកបញ្ជាបងឲ្យធ្វើការអស់ហ្នឹង ធ្វើកិច្ចការហ្នឹង?

លន់៖ បើខ្ញុំឆ្លើយខ្ញុំគិតថា មានតែមេកងមេស្រុកហ្នឹងគេបញ្ជា ។

កុសល៖ ចឹងបងប្រាប់មេកងឈ្មោះ ដែលបង?

លន់៖ មេកងខ្ញុំឈ្មោះយុន យឿត ។

កុសល៖ ចឹងសូមបងរៀបរាប់តទៀតបង កាល៧៩បងចេញទៅតាមគេហ្នឹងបង?

លន់៖ បាទ! នៅពេលស្រុកបែកបាក់ទៅក៏រត់ទៅនៅស្រុកអំពិល បន្ទាយអំពិល ។

កុសល៖ បាទ ។

លន់៖ ដល់ក្រោយមកដុំខែ៧បានកំលាំងខ្មែរក្រហមប្រមូលគ្នាណាស់ បានខ្ញុំមកនៅអន្លង់មុតដល់ចុងខែ៧បាន ដល់ចុងខែ៧បានគេឲ្យខ្ញុំមកនៅភ្នំរូងដែកយើងបាទ ។

កុសល៖ បាទ ។

លន់៖ ដល់ខែ៨ខែ៩បានគេឲ្យខ្ញុំទៅ៨០៨ ។

កុសល៖ កងពលទេបង?

លន់៖ អត់ទេ ចាំមើលខ្ញុំនិយាយឲ្យស្តាប់ ក្រោយពីខ្ញុំបែកចេញពីខាងស្រុកគេបញ្ជូនឲ្យខ្ញុំនេះមកនៅកន្លែងកងពល ។

កុសល៖ បាទ ។

លន់៖ ដល់នៅកន្លែងកងពលនេះ ខ្ញុំក៏នៅជាកងពិសេសកន្លែងកងពល ។

កុសល៖ កងពលពិសេសឆ្នាំណា?

លន់៖ នៅឆ្នាំ១៩៧៩ ខែ៨ ។

កុសល៖ ចឹងនៅឆ្នាំ១៩៧៩ហ្នឹង គេហៅកងពលអី?

លន់៖ គេហៅកងពលឧត្តរ ។

កុសល៖ ចឹងគិតពីជំនាន់ហ្នឹងវិញ ពូមានគិតឃើញ បងដែលមានយោសព្វឃើញជំនាន់ហ្នឹងដែលទេបង?

លន់៖ មានដែលព្រោះថា កន្លែងដែលជួបប្រទះនៅកាលលំបាកគ្រប់បែបយ៉ាងទាំងអស់ណាស់ ។

កុសល៖ បាទ ។

លន់ៈ មានពេលខ្លះដេកយោសព្វសម័យឃើញកំសត់ដែលណាស់ ។

កុសលៈ ចឹងឧទាហរណ៍បងយោសព្វឃើញអីខ្លះ?

លន់ៈ យោសព្វពីការលំបាកកាលសម័យនោះ ម៉ាផ្នែកនៅក្រោមទិរ៉ាតរបស់គេយើងអត់បាយ អត់ទឹកគេប្រើយើងទាំងយប់ទាំងថ្ងៃនោះណាស់ ។

កុសលៈ ចឹងយោសព្វអាក្រក់?

លន់ៈ ហ្នឹងហើយយោសព្វអាក្រក់ ។

កុសលៈ ចឹងកន្លងមកការទំនាក់ទំនងជាមួយអ្នកជិតខាងមានការជិតស្និតដែលទេបង?

លន់ៈ ខ្ញុំមិនសូវមានពួកម៉ាកមិត្តភក្តិអីទេ មិនសូវមានអ្នកជិតស្និតនិងខ្ញុំទេ ។

កុសលៈ ហេតុអីទៅបង ។

លន់ៈ ព្រោះខ្ញុំបានប្រកាន់ខ្លួនខ្ញុំថា មិនយកខ្លើឬមិត្តភក្តិហ្នឹងតែម្តង ។

កុសលៈ ហេតុអីយើងខ្វះការទុកចិត្តពីរបបមុនមកឬយ៉ាងម៉េច?

លន់ៈ ព្រោះខ្ញុំគិតថា មិនមានអ្នកណាដែលមានចិត្តដូចគ្នា ចិត្តដូចខ្ញុំបានជាខ្ញុំមិនយកខ្លើឬមិត្តភក្តិអី ណាស់ មិនយកខ្លើ ។

កុសលៈ ចឹងដូចថា បងមិនសូវយកមិត្តភក្តិជិតស្និតហ្នឹង ខ្ញុំអាចដាក់ថាតិចតួចឬគ្មានសោះ?

លន់ៈ តិចតួចបាន ។

កុសលៈ ចឹងបងមានភ្ញាក់អារម្មណ៍មានពេលខ្លះឆាប់ភ្ញាក់ផ្អើល ភ័យខ្លាចដែលទេ?

លន់ៈ មានដែរ ។

កុសលៈ មានខ្លាំង តិច បន្តួរ ឬក៏ខ្លាំងណាស់បង?

លន់ៈ បើគិតទៅវាមិនខ្លាំងអីប៉ុន្មានទេ ។

កុសលៈ ចឹងខ្ញុំដាក់ខ្លាំងបន្តួរណាស់?

លន់ៈ បាទ ។

កុសលៈ បងមានការលំបាកធ្ងិតធ្ងន់ទៅលើការងារដែលបង?

លន់ៈ ក្នុងសម័យនោះខ្ញុំគិតថា កាលមិនបានចប់សង្រ្គាមណាស់ ។

កុសលៈ បាទ ។

លន់ៈ ខ្ញុំអត់មានគិតគូរតួនាទីការងារអីទេ ខ្ញុំស្តាប់តែបញ្ជាគេឲ្យធ្វើអីធ្វើនោះ ដើម្បីខ្លួនខ្ញុំរស់បាន សុខ តែប៉ុណ្ណឹងទេ ។

កុសលៈ តែខ្ញុំចង់និយាយក្រោយមកបង?

លន់ៈ បានត្រឹមក្រោយនេះបានខ្ញុំចង់ បានត្រឹម៩៨មក ។

កុសលៈ ចង់បានតួនាទី?

លន់ៈ ឯតួនាទីនោះក៏ខ្ញុំមិនចង់បានប៉ុន្មានទេ តែគ្រាន់ថាខ្ញុំមិនអាចជៀសផុត ខ្ញុំចង់និយាយបន្តិចថា ពី៧៩មកដល់ប៉ៃតមកដល់កៅជាពេលវេលាវែងបំផុត ពិតមែនតែខ្ញុំមិនមានតួនាទីអីទេ តែថាការងារអីខ្ញុំធ្វើបានច្រើនណាស់ ព្រោះកាលពីឆ្នាំ៧៩ គេឲ្យខ្ញុំទៅនៅ៨០៨ កាលនោះខ្ញុំនៅជាមួយមេដែរ ។

កុសលៈ បាទ ។

លន់ៈ តែគេឲ្យខ្ញុំមកចាំឃ្លាំង ដល់ឆ្នាំ៨០បានគេដកខ្ញុំឲ្យទៅនៅខាងភូមិភាគកណ្តាល ទៅនៅខាង ១០០១ ឆ្នាំ៨១ គេឲ្យខ្ញុំទៅនៅកំពង់ចាម៦ឆ្នាំ ។

កុសលៈ ចឹងកាលដកបងជិនាន់ហ្នឹង គេអត់ឲ្យបងទៅវៃជាមួយវៀតណាមទេ?

លន់ៈ អត់ទេ ពួកខ្មែរយើងអត់សូវមានបានទៅទេ ភាគច្រើនគេឲ្យចាំតែច្រកហ្នឹង ធ្លាប់តែធ្វើសកម្មភាពតែខាងនេះទេ ។

កុសលៈ ចឹងខាងថៃមានលុកលុយមកលើប្រទេសយើងទេ?

លន់ៈ កាលជំនាន់ហ្នឹងយើងវៃល្បើកដល់ណាអីដែលហ្នឹង កាលឆ្នាំ៧៧ថៃជាយដែន ។

កុសលៈ ចឹងថៃជាដែនហ្នឹងក៏មានការលុកលុយមកប្រទេសយើងដែរ?

លន់ៈ គេអត់មានលុកលុយមកលើប្រទេសយើងទេ បើគិតឲ្យដល់ តែថាយើងវៃពួកសេសសល់នោះ គេហៅថាពួកលន់ នល់ អ៊ិន តាំនោះ ។

កុសលៈ ហ្នឹងខាងអ៊ិន តាំនៅខាងនោះត្រូវហើយ ។

លន់ៈ ជាប់នៅជាយដែននោះ ។

កុសលៈ បាទ!ពួកហ្នឹងមានសកម្មភាពខ្លាំងដែលពួកអ៊ិន តា ហ្នឹង?

លន់ៈ កាលហ្នឹងខ្លាំងដែលកាលមួយសានោះណាស់ ។

កុសលៈ ចឹងបងធ្លាប់ចូលប្រឡូកវៃជាមួយពួកហ្នឹងដែលឬមួយយ៉ាងម៉េច?

លន់ៈ ធ្លាប់វៃដែរ ។

កុសលៈ ពួកហ្នឹងបានជំនួយពីថៃមកឬមួយយ៉ាងម៉េច?

លន់ៈ បាទ!ពីថៃមកគាំទ្រដោយអាមេរិច ។

កុសលៈ ចឹងមួយក្រុមទៀតខ្ញុំឮថា ពីថៃកុម្មុយនីស្តដែរ មានដែរ បងមានធ្លាប់ឮដែលទេ ពួកថៃគេមានបក្សកុម្មុយនីស្តរបស់គេ?

លន់ៈ មាន ។

កុសលៈ តែជាមួយវៀតណាមអត់មានទាក់ទងជាមួយកងទ័ពវៀតណាមទេនៅពេលហ្នឹង?

លន់៖ អត់ទេ ។

កុសល៖ ចឹងបងមានធ្លាប់ធ្វើសង្គ្រាមជាមួយវៀតណាមឆ្នាំ៧៧អីវ៉ាន់ខ្លាំងទេ?

លន់៖ មានដឹងមានពុទ្ធាំងអស់ តែគ្រាន់ថាអត្តភាពខាងខ្ញុំនេះអត់មានទៅទេ ខាងខត្តរយើងនេះណាស់ ។

កុសល៖ បាទ!ចឹងដូចជាបងដឹងស្រាប់ហើយពួកនិរតីគេចាប់ម៉ាគំនរ ជំនាន់ហ្នឹងដោយសារមានវ៉ៃសង្គ្រាមជាមួយវៀតណាមចឹង ជាពិសេសកម្មាភិបាលខាងៗគេចាប់ណាស់ ដូចជាលោកឌុចនេះបញ្ជាឲ្យចាប់ច្រើន?

លន់៖ បាទ ។

កុសល៖ ចឹងបងសង្គ្រាមបងមិនសូវបានទៅខាងនោះទេ ភាគច្រើនទាក់ទងនិងខាងនេះ?

លន់៖ បាទ!ទាក់ទងតែខាងនេះ ។

កុសល៖ ចឹងខ្ញុំសួរបងដូចឆ្ងល់ បន្ទាប់ពីហ្នឹងបងមានដែលគិតថា មានអារម្មណ៍ថា មិនទុកចិត្តគេ ថាមេៗគេចាប់អីចឹង?

លន់៖ ខ្ញុំមិនទុកចិត្តតែរហូតតាំងពីឆ្នាំ៧៧មកម្ល៉េះ ពិសេសគេហៅថា ជំនាន់ពួកនិរតីនោះណាស់ខ្ញុំមិនទុកចិត្តរហូត រហូតដល់ខ្ញុំអត់យកមិត្តយកភក្តិហ្នឹងណាស់ ខ្ញុំមិនជឿគេ ។

កុសល៖ ចឹងកន្លែងហ្នឹងមួយជាចំណុចសំខាន់ណាបងណាស់?

លន់៖ បាទ ។

កុសល៖ ចឹងបងជៀសវាងនៃការគិតគូពីរបបហ្នឹងដែលទេ?

លន់៖ បើសិនណាបើជៀសបានផុត ជៀសឲ្យផុតហើយដាក់ផែនការដល់កូនចៅត្រូវជៀសឲ្យផុត ។

កុសល៖ ជៀសឲ្យផុតកុំឲ្យគិតរឿងហ្នឹង?

លន់៖ កុំឲ្យមានគិតកុំឲ្យមានអារម្មណ៍សម័យទៅអារបបហ្នឹង ។

កុសល៖ ចឹងបន្ទាប់ពីរបបហ្នឹងមក សម័យសមាហរណ៍កម្មឆ្នាំ៩៧-៩៨មកបងមានអារម្មណ៍នៅមានសង្ឃឹមជាងមុនឬមួយយ៉ាងម៉េច?

លន់៖ សង្ឃឹមទៅលើអី?

កុសល៖ ទៅលើអនាគតប្រទេសជាតិយើងទៅលើ ដូចថាកូនចៅរបស់បង?

លន់៖ បាទ!ត្រឹមត្រូវហើយ សមាហរណ៍កម្មហើយខ្ញុំគិតថា ពពកខ្មៅងងឹតដែលវាធ្លាប់តែគ្របដណ្តប់មកច្រើនឆ្នាំខ្ញុំគិតថា បានធ្វើឲ្យអារម្មណ៍ខ្ញុំ ចិត្តខ្ញុំ ភ្នែកខ្ញុំមើលឃើញថា វាស្រឡះអស់ហើយ បានថា ស្រឡះពីព្រោះថា វាចូលដល់ថាប្រទេសជាតិបានបង្រួបបង្រួមបាន

សន្តិភាព ដល់ចឹងទៅខ្ញុំនេះក៏មានគេហៅថាស្មារតីម្យ៉ាងនិយាយថា គិតគូរដល់អ្នកភូមិខ្លួនឯង ណាស់ ។

កុសលៈ បាទ ។

លន់ៈ ព្រោះថា ខ្ញុំកើតមេភូមិនេះវាស្មើនិងពីរជំនាន់ដែរ កាលពីសម័យតា ម៉ុកនោះខ្ញុំធ្វើ៥ឆ្នាំ មេស្រុកគេបោះឆ្នោតឲ្យ ។

កុសលៈ ធ្វើមេភូមិ?

លន់ៈ បាទ!ដល់ចប់សង្រ្គាមទៅសមាហរណ៍កម្មហើយ ខ្ញុំក៏ផ្តាច់ខ្លួនទៅធ្វើកងទ័ពមួយខែ ដល់នេះ ទៅអ្នកស្រុកគេអត់មានមេភូមិក៏គេបោះឆ្នោតឲ្យខ្ញុំជាប់មួយសារទៀត ខ្ញុំក៏ផ្តាច់ខ្លួនមកពីកង ទ័ពមកបំរើគេរហូតមកដល់សព្វថ្ងៃនេះ ក្រោយពីសិទ្ធសេរីភាពមានខ្ញុំក៏ចាប់ផ្តើមពង្រីក ការ ទំនាក់ទំនងជាមួយ ពីដើមឡើយក្នុងសង្រ្គាមគេហៅថា យុទ្ធមិត្តណាស់ ។

កុសលៈ បាទ ។

លន់ៈ ឬមិត្តភក្តិមួយចំនួនដែលធ្លាប់ស្គាល់គ្នាពីសម័យសង្រ្គាមនោះ អ្នកខ្លះក៏គេបានទៅធ្វើការធំ ទៅ ។

កុសលៈ ចឹងបងចូលមកជំនាន់បង ផាន់ ណាហ្នឹងមែនទេ?

លន់ៈ ទង់ទេ ខ្ញុំមកក្រោយ ។

កុសលៈ ចឹងបងផាន់ ណាមកមុន?

លន់ៈ បាទ! បងផាន់ ណាមកមុន ។

កុសលៈ បងយឹម តុន គាត់មកមុនសេរីគាត់ហ្នឹង ។

លន់ៈ បាទ!បងជាមួយបងផាន់ ណាហ្នឹងឯង បានពង្រីកខ្លួនទំនាក់ទំនងជាមួយអង្គការក្រៅ ដើម្បី រកការទំនាក់ទំនងមកអភិវឌ្ឍន៍ភូមិស្រុក ។

កុសលៈ ចឹងក្នុងភូមិយើងតាំងពីហ្នឹងមក បងការរីកចំរើនផ្នែកសេដ្ឋកិច្ចដូចថា វាដល់កំរិតណាទៅ ហើយតាមបងយល់ យើងនៅខ្វះខាតអីខ្លះ រឿងបញ្ហាសេដ្ឋកិច្ចនៅក្នុងតំបន់នេះ អ្នកភូមិ យើងនៅមានខ្វះអីខ្លះ?

លន់ៈ ខ្ញុំគិតថា បើខ្ញុំបានតាមដានជាប្រាកដពីមួយឆ្នាំទៅមួយឆ្នាំ ខ្ញុំគិតថាខ្វះខាតពីឆ្នាំដំបូងនៅឆ្នាំ ៩៩ ភូមិខ្ញុំមានការលំបាកបំផុត ព្រោះខ្ញុំបានប្រៀបធៀបហើយថា បើសិនណាអ្នកដែល ការថ្មីដែលបែកពីឪពុកម្តាយនោះណាស់ រមែងតែងថា ម៉ែឪទាំងសងខាងតែងតែចាងចាន បែកឆ្នាំង ស្លាបព្រាឲ្យកូនគេណាស់ ។

កុសលៈ បាទ ។

លន់៖ តែខ្ញុំក្រោយពីសមាហរណ៍កម្មអត់មានអីទេ អ្នកភូមិខ្ញុំក៏អត់ ខ្ញុំក៏អត់ប៉ុន្តែដោយយោងទៅតាមភូមិសាស្ត្រប្រកបទៅដោយភូមិសាស្ត្រយើងក្នុងស្រុកសម័យឆ្នាំនោះវាសម្បូរធនធានដល់ចឹងទៅយើងក៏ស្រួបយកធនធានដែលយើងមានហ្នឹង យកទៅចិញ្ចឹមជីវិតក្នុងរយៈមួយឆ្នាំពីរឆ្នាំ បានយើងមានសេដ្ឋកិច្ចហៅថា មានលំហ្នឹងណាស់ ។

កុសលៈ បាទ ។

លន់៖ ដោយយើងមានឱកាសធ្វើស្រែពេញកំលាំងរបស់យើង ធ្វើស្រែធ្វើចម្ការនិងទៅហើយមកក្នុងឆ្នាំ៩៩ឆ្នាំ២០០០ឆ្នាំ២០០១មករហូតដល់ឆ្នាំ២០០៣ បានសភាពការណ៍ដីវាមានហាងឆេង ដល់ចឹងទៅកាលពីឆ្នាំ៩៩ ខ្ញុំបានវាល់ដីជូនអ្នកស្រុកតាមដងផ្លូវហ្នឹងកំណត់ឲ្យមួយគ្រួសារហ្នឹងស្មើនិង៥០ម៉ែត្រ បណ្តោយទៅក្រោយវាអត់មានកំណត់ទេ កុំឲ្យតែទៅប៉ះរបស់គេ ។

កុសលៈ បាទ ។

លន់៖ ហ្នឹងកាលពីគោលការណ៍ដើម តែដល់ពេលដីមានហាងឆេងនៅឆ្នាំ២០០៤ឆ្នាំ២០០៥ហ្នឹងខ្ញុំក៏គិតឃើញថា មួយជាតិហើយដែលវាលំបាកនោះ ពេលនេះយើងមានឱកាសហើយចឹងបងប្អូនបានលក់មានទំនាក់ទំនងវិញដូចគ្នាគេទៅ ។

កុសលៈ បាទ ។

លន់៖ តែក៏ខ្ញុំមានវិធានការដែរ ដីខ្ញុំចែកមួយប្លង់ស្មើ៥០ម៉ែត្រ បើសិនជាមានអ្នកណាមកលក់ទាំងអស់ខ្ញុំមិនធ្វើច្បាប់ឲ្យ ខ្ញុំចង់ឲ្យតែគេលក់តែមួយខាងៗ ខ្ញុំសម្ភាសជាមួយគេថែមទៀតថា យើងលំបាកពីនោះមកដល់នេះ យើងលក់យកលុយមកច្រើនម្ល៉េះយកទៅធ្វើអីខ្លះ ។

កុសលៈ បាទ!ចឹងអ្នកស្រុកអ្នកភូមិក្នុងភូមិបងហ្នឹង ថាតើមានប្រជាជនប៉ុន្មាននាក់?

លន់៖ មកដល់ឥឡូវមានដល់ទៅ៩០០នាក់ទៅហើយ ។

កុសលៈ នេះសៀវភៅសត្តិភូមិ៩០០នាក់ ។

លន់៖ ស្រីមានប៉ុន្មានទេ ៤៥៧នាក់ ប្រុស៤៣៣នាក់ ។

កុសលៈ នៅហ្នឹងមុខរបរជាធំមុខរបរអីគេទៅ?

លន់៖ មុខរបរអ្នកភូមិខ្ញុំនេះ បច្ចុប្បន្នពីនោះមកដល់នេះគឺដំណាំស្រូវ ។

កុសលៈ ដំណាំស្រូវបងប្អូករួមទាំងចម្ការដែលប្តូមួយយ៉ាងម៉េច?

លន់៖ ចម្ការស្រូវដែរ ។

កុសលៈ ដំឡូង?

លន់៖ ដំឡូងទើបនិងឆ្នាំនេះទេ ឆ្នាំមុននិងឆ្នាំនេះពីរឆ្នាំ ។

កុសលៈ ចឹងសមាសភាពប្រជាជនមកពីខាងក្នុងឬមួយប្រជាជននៅតំបន់នេះភាគច្រើន?

លន់ៈ កាលពីដើមឡើយខ្ញុំអាចនិយាយពីរបានណាស់ ។

កុសលៈ បាទ ។

លន់ៈ ការពីខ្ញុំទទួលគ្រប់គ្រងពីសម័យនោះ នៅក្នុងភូមិនេះមានតែ៧៧គ្រួសារទេ នៅឆ្នាំ១៩៩៨ ពីមុនដល់៩៨ ឆ្នាំ៩៥ ឆ្នាំ៩៧និង៩៨ហ្នឹងណាស់ ។

កុសលៈ បាទ!មានប៉ុន្មានគ្រួសារ?

លន់ៈ មាន៧៧គ្រួសារ កំលាំងមានតែ៤១០នាក់ទេ ។

កុសលៈ ចឹងបងក្តាប់បានច្បាស់?

លន់ៈ បាទ ។

កុសលៈ ចឹងដល់ក្រោយមកហ្នឹងសុទ្ធតែអ្នកមកពីក្រៅទាំងអស់?

លន់ៈ តែដល់បច្ចុប្បន្ននេះកំលាំងខាងខ្ញុំក៏រីកហើយកំលាំងខាងក្នុងក៏ច្រើនដែរ ។

កុសលៈ ចឹងឥឡូវមានប៉ុន្មានគ្រួសារបង?

លន់ៈ មកដល់ឥឡូវនេះមានច្រើនដែលហើយ មាន១៨៩គ្រួសារ ។

កុសលៈ ចឹងមានប្រជាជនទៅដល់៩០០នាក់?

លន់ៈ បាទ ។

កុសលៈ ចឹងឡើងមួយជាពីរចឹង?

លន់ៈ បាទ ។

កុសលៈ ចឹងអាចមានឡើងបន្តមកឡើងមកទៀតហើយ ព្រោះត្រូវដំឡូងអីចឹង ដីថ្លៃបានមក?

លន់ៈ បាទ ។

កុសលៈ ចឹងខ្ញុំសួរមួយទៀតទាក់ទងនិងការទំនុកចិត្ត ដូចការគិតគូពីអ្នកភូមិជាមួយគ្នាបង?

លន់ៈ បាទ ។

កុសលៈ ចឹងបងគិតថា អ្នកភូមិយើងមានការទុកចិត្តគ្នាទៅវិញទៅមករវាងអ្នកជិតខាងនិងអ្នកជិតខាង ទុកចិត្តរវាងគ្នាដល់កំរិតណាដែរ?

លន់ៈ ទាក់ទងទៅនិងអ្នកភូមិខ្ញុំ ខ្ញុំគិតថា ។

កុសលៈ ព្រោះថ្ងៃមុនខ្ញុំចាប់អារម្មណ៍ឃើញមកជួបថ្ងៃមុនណាស់បង ខ្ញុំចង់សួរថា តើការទុកចិត្តរវាងគ្នានិងគ្នាហ្នឹងមានកំរិតណាដែរ?

លន់ៈ បើសិនណាក្រៅពីភូមិខ្ញុំក៏ខ្ញុំមិនអាចកំណត់បានដែរ ។

កុសលៈ បាទ ។

លន់៖ សម្រាប់តែភូមិខ្ញុំ ខ្ញុំគិតថា បើគិតជាភាពសាមគ្គីគ្នា មិនមែនត្រឹមនេះទេ វាមានមកតាំងពីមិនទាន់ចប់សង្គ្រាមមកម៉េះ តាំងពីសម័យខ្ញុំធ្វើមេភូមិ ។

កុសលៈ បាទ ។

លន់៖ ពីឆ្នាំ៩៥មក មកដល់ឆ្នាំ២០០០វាស្មើនិង៥ឆ្នាំហើយមកដល់ឥឡូវនេះ២០១១នេះវាច្រើនឆ្នាំដែលហើយណា ។

កុសលៈ បាទ ។

លន់៖ អ្នកស្រុកទាំងអស់នេះ ខ្ញុំគិតថាបងប្អូននៅមានគតិសាមគ្គីគ្នាវេចីនណាស់ នៅមានទំនុកចិត្តលើគ្នាច្រើន ។

កុសលៈ បាទ ។

លន់៖ បើយើងគិតអាចនិយាយបានថា វាជិតទៅ៨០ភាគរយនោះ ដែលទុកចិត្តគ្នាណាស់ ។

កុសលៈ ចឹងចំពោះបងផ្ទាល់បងមានម្ចាស់ការលើខ្លួនឯងជាងដល់កំរិតណាដែរ?

លន់៖ បើនិយាយពីសភាពម្ចាស់ការខ្ញុំគិតថា ខ្ញុំមានសភាពម្ចាស់ការខ្ពស់ជាងគេសើច... ។

កុសលៈ បាទ!ចឹងបងគិតថា មានទំនុកចិត្តទៅលើរដ្ឋាភិបាលបច្ចុប្បន្នប៉ុណ្ណាដែរ?

លន់៖ ចំពោះរដ្ឋាភិបាលខ្ញុំមានទំនុកចិត្តមួយរយភាគរយ ។

កុសលៈ ចឹងបងគិតថា រដ្ឋាភិបាលហ្នឹងបានផ្តល់ភាពយុត្តិធម៌ដល់ការគ្រប់គ្រងតំបន់ភូមិហ្នឹងដែលអត់ ចង់និយាយថា ការជំនួយស្រុកភូមិហ្នឹងវាគ្រប់គ្រាន់ដែលដល់កំរិតណា ឬក៏ខ្វះខាតយ៉ាងខ្លះ?

លន់៖ កន្លែងហ្នឹងខ្ញុំមិនអាចនិយាយបានទេ ត្រង់ថា បញ្ហាខ្វះជាជំនួយអ៊ីៗមិនដែលបានទទួលទេ ។

កុសលៈ បាទ ។

លន់៖ បើនិយាយពីភាពកក់ក្តៅណាស់មាន ។

កុសលៈ ការចូលរួមប្រជាពលរដ្ឋនៅពេលបច្ចុប្បន្ន ចឹងអ្នកស្រុកអ្នកភូមិយើងមានការចូលរួមសកម្មការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ស្រុកភូមិដល់កំរិតណាដែរ?

លន់៖ សម្រាប់ភូមិខ្ញុំនេះ បើគិតទៅ ទើបជាច់មួយរយៈទេ កាលឆ្នាំយើង២០០៦ឆ្នាំ២០០៧ឆ្នាំ២០០៨ហ្នឹង ការរួមសាមគ្គីគ្នាក្នុងសហគមន៍មានសន្ទុះល្អណាស់ ។

កុសលៈ ចឹងពួកគាត់ក៏គាំទ្រនយោបាយរដ្ឋាភិបាលដែលឬមួយយ៉ាងម៉េច?

លន់៖ គាំទ្រគោលនយោបាយរដ្ឋាភិបាលនិងសហគមន៍ណាស់ ទើបឆ្នាំ២០០៨ឆ្នាំ២០០៩នេះពេលដែលសភាពព្រំដែនវាលំបាកទៅ សហគមន៍ហាក់បីដូចឃ្លាតពីគ្នាបន្តិច ត្រង់ថាមិនសូវមានឱកាសក្នុងការធ្វើការងាររួមគ្នា ដល់យើងចាប់អារម្មណ៍រឿងជាយដែននេះ ។

កុសលៈ បាទ ។

លន់ៈ ខ្លាចគ្រាប់គេវ៉ៃគ្នានោះណាស់ តែក្រោយពីប៉ុន្មានខែមកនេះ ខ្ញុំគិតថាសហគមន៍ខ្ញុំដូចជាដំណើរការវិញហើយ មានធ្វើការរួមគ្នា ។

កុសលៈ បាទ ។

លន់ៈ គ្មានបញ្ហាអីទេ ខ្ញុំគិតថា ភូមិខ្ញុំគ្រាន់បើជាងភូមិគេបន្តិចហើយ ។

កុសលៈ ចឹង?

លន់ៈ បាទ ។

កុសលៈ ចឹងសំនួរមួយទៀតប្រជាជនមានការរិះគន់កែលម្អដល់គោលនយោបាយស្រុកភូមិដែលទេ មានការចូលរួម ឧបមាថាភូមិទទួលការងារពីរដ្ឋាភិបាលមក យើងមានប្រជុំជាមួយប្រជាជន ប្រជាជនគាត់មានលើកការរិះគន់ឬការឲ្យយោបល់ផ្សេងក្នុងការចូលរួមអភិវឌ្ឍន៍ស្រុកភូមិដែលឬទេ?

លន់ៈ ទាក់ទងទៅការប្រជុំពិគ្រោះយោបល់ ខ្ញុំគិតថាមេភូមិខ្ញុំមានដែរ ។

កុសលៈ ចឹង?

លន់ៈ បាទ!មានការពិគ្រោះយោបល់សួរនាំគ្នាណាស់ ទាក់ទងទៅហ្នឹងបញ្ហា ។

កុសលៈ បាទ!ពីកំរិត១ដល់កំរិត៥ តើថាគាត់ចូលរួមដល់កំរិតណា ១តិច៥ច្រើនបំផុត?

លន់ៈ បើនិយាយអ្នកដែលហៅថា អ្នកនិយាយវែកញែកសួរនាំហេតុផលណាស់ ។

កុសលៈ បាទ ។

លន់ៈ យើងឧបមាថា យើងមានគ្នាទៅដល់១០នាក់ អ្នកដែលហ៊ានបញ្ចេញមានមួយឬពីរនាក់តែប៉ុណ្ណឹងទេ ។

កុសលៈ ចឹងនៅមានតិចបង វាតិច?

លន់ៈ បាទ!បើសិនជាទាក់ទងទៅនិងការអភិវឌ្ឍន៍ គឺគំរោងការនៃការអភិវឌ្ឍន៍បងប្អូនគេមានមតិច្រើនទៅវិញ ។

កុសលៈ ចឹងវិញ?

លន់ៈ ឧទាហរណ៍ថា បើសិនណាមាន១០នាក់ប្រជុំចេះ អាចមានទៅ៧នាក់គេមានមតិយោបល់ពិគ្រោះជាមួយយើង ។

កុសលៈ ចឹងបានខ្ញុំដាក់៥ច្រើនទៅវិញទាក់ទងនិងការអភិវឌ្ឍន៍ស្រុកភូមិ?

លន់ៈ បាទ ។

កុសលៈ ចឹងសំនួរនេះខ្ញុំចង់សួរចំពោះបងផ្ទាល់ ដូចបងបានលើកពីមុនមកហើយ បងជាប្រធានភូមិ ស្រាប់ដូចបានឆ្លើយនិងសំនួររួចហើយ តើការចូលរួមបម្រើស្រុកភូមិបងបានចូលរួមដល់កំរិតណាដូចនេះ បងស្មោះសត្រ័ដល់កំរិតណា?

លន់ៈ ចឹងសម្រាប់ខ្ញុំ ។

កុសលៈ បាទ ។

លន់ៈ សម្រាប់ខ្ញុំ ខ្ញុំចង់និយាយឲ្យវែងបន្តិច ខ្ញុំគិតថា ខ្ញុំតែងយកការឈឺចាប់របស់ខ្ញុំទៅបម្រើឲ្យបងប្អូនក្នុងសហគមន៍ ព្រោះខ្ញុំគិតថា បងប្អូនដែលនៅក្រោមទិវិាគខ្ញុំនេះវាមាន វាគិតទៅថាយូរឆ្នាំណាស់មកហើយ ជាង១០ឆ្នាំ បើចឹងយកការឈឺចាប់យកការអត់ឃ្លានឬការជួបប្រទះរបស់យើង គ្រួសារអ្នកភូមិមកស្មើនិងការឈឺចាប់របស់ខ្លួនដែលធ្លាប់មាន ចឹងបានសេចក្តីថា ខ្ញុំចាប់អារម្មណ៍ទៅលើការរស់នៅនិងសុខភាពរបស់អ្នកភូមិ ជាពិសេសនៅពេលរដូវប្រាំងជួបលំបាកអី ពេលរដូវវស្សាជួបលំបាកអី តែងតែលើកយកវិធានការរបស់ខ្លួនមាននេះ ។

កុសលៈ បាទ ។

លន់ៈ ទៅបំភ្លឺឲ្យគេ ដើម្បីឲ្យគេនេះ បេះរកវិធីដោះស្រាយ ម្យ៉ាងទៀតខំកខំទំនាក់ទំនងជាមួយអង្គការផ្សេងៗដើម្បីសុំជំនួយរបស់គេមកផ្តល់ឲ្យបងប្អូនទាំងអស់ហ្នឹង ។

កុសលៈ ខ្ញុំឃើញថ្ងៃមុន ។

លន់ៈ បាទ! តាមការពិតខ្ញុំនេះ អន់ណាស់ទៅហើយ បើនិយាយក្នុងសង្គមកេប្រមាថគេមើលងាយ គេជេរស្តីណាស់ ។

កុសលៈ បាទ ។

លន់ៈ ប៉ុន្តែការឈឺចាប់ទាំងអស់នេះ ខ្ញុំយកមកបម្រើឲ្យបងប្អូនទៅវិញ ។

កុសលៈ ហេតុអីបងគិតថា គេជេរប្រមាថ គេជេរស្តី?

លន់ៈ ព្រោះក្នុងនាមយើងជាជនពិការ បាត់បង់អស់នៅអវៈយៈវៈសូម្បីយើងឡើងទៅរោងជំនុំឬការងារអីផ្សេងៗក្នុងចំណែក តើយើងមានសមត្ថភាពស្មើគេដែលអត់ទេ ពីព្រោះថា យើងបាត់បង់អវៈយៈវៈអស់ទៅហើយ ។

កុសលៈ ប៉ុន្តែការបាត់បង់អវៈយៈវៈជារឿងផ្សេង តែការគិតគំនិតរបស់បងវាផ្សេងគ្នា ទ្រឹស្តីផ្សេងគ្នា ។

លន់ៈ វាជារឿងផ្សេងមែន តែធ្លាប់ទទួលបានការមើលងាយ ។

កុសលៈ ពីថ្នាក់ណា?

លន់៖ ពីមជ្ឈដ្ឋានសង្គម ប៉ុនគិតសម្រាប់ខ្ញុំ គេមើលឆ្ងាយទៅចុះ តែខ្ញុំមិនត្រូវការមើលឆ្ងាយគេ ខ្ញុំត្រូវការយកចិត្តទុកដាក់ទៅលើពួកដែលយ៉ាប់យឺនដាងខ្ញុំ ប្រែក្លាយការឈឺចាប់នេះឲ្យទៅជាកំលាំងប្រយុទ្ធដើម្បីការអភិវឌ្ឍន៍នៅក្នុងភូមិស្រុក ។

កុសលៈ ចឹងទាក់ទងការអភិវឌ្ឍន៍ក្នុងភូមិស្រុកហ្នឹង ខ្ញុំចង់សួរបងបន្ថែមទៀត សួរថាតើ យើងជាប្រជាជនយើងគួរគោរពតាមរដ្ឋាភិបាលដោយគ្មានការរិះគន់សុទ្ធសាធឬថាយើង បើរដ្ឋាភិបាលដាក់បញ្ហាថា ការងារនេះជាការងារអភិវឌ្ឍន៍ យើងត្រូវតែគោរពតាមដល់កំរិតណា ឬយើងគួរតែមានការរិះគន់ដែរ?

លន់៖ វាមានលក្ខណៈពីរយ៉ាងបាទ បើសិនណាយើងមើលទៅមានការឯកភាពលើផលប្រយោជន៍ស្រុកភូមិរបស់យើង យើងមិនត្រូវទៅជំទាស់ឬមួយតវ៉ាអីទេ តែបើទាក់ទងនិងបញ្ហាខ្លះធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍ប្រជាជន យើងត្រូវតែជំនាស់ដែរ ។

កុសលៈ បាទ ។

លន់៖ ចឹងវាមានពីរណាស់ ។

កុសលៈ ចឹងយើងគោរពតាមបើយើងយល់ថាត្រឹមត្រូវ បើសិនជាមិនប៉ះពាល់?

លន់៖ បាទ ។

កុសលៈ ជួបកាលទៅរដ្ឋាភិបាលនៅភ្នំពេញឆ្ងាយខ្ញុំនិយាយជាមួយបង ផាន់ ណា ជួនកាលទៅគាត់អត់យល់សម្រេចពីលើមកចឹងដាក់មកក្រោមចឹងវាអាចប៉ះពាល់ដីធ្លីហ្នឹងរាប់រយហិចតាឲ្យទៅក្រុមហ៊ុនផ្សេងៗនេះអាចប៉ះពាល់ដល់ប្រជាជនភូមិឃុំគាត់អត់បានដឹងណាស់ ក្រុមហ៊ុនចុះមកគេដឹងតែផលប្រយោជន៍របស់គេ ចុះទាក់ទងមាគ៌ាព្រះពុទ្ធទាំង៥យ៉ាង តើបងយល់ថាប្រជាជននៅក្នុងភូមិបងហ្នឹងគោរពតាមសាសនាដល់កំរិតណាដែរ?

លន់៖ ទាក់ទងទៅលើការជំនឿទៅលើព្រះពុទ្ធសាសនា គិតថាបេះ ពួកខ្ញុំធ្លាប់តែខ្មែរក្រហមណាស់ ។

កុសលៈ បាទ ។

លន់៖ មកនៅក្រោយច្បាប់ទៀត មិនសូវបានទទួលគេហៅការព្រានប្រដៅនេះខាងផ្លូវធម៌ទេ ក៏ប៉ុន្តែខ្ញុំជឿថាបានម្យ៉ាង ចង់និយាយថា ពួកខ្ញុំការរស់នៅសម័យនោះវាមានសីលធម៌គុណធម៌ល្អអត់មានបេះលួចឆក់ប្លន់គ្នាទេ ។

កុសលៈ ត្រូវហើយជំនាន់ហ្នឹង ។

លន់៖ សីលធម៌គុណធម៌ល្អណាស់ មិនតែប៉ុណ្ណោះសាមគ្គីគ្នាក៏បានល្អ ។

កុសលៈ ចឹងជាគុណធម៌មួយមិនចាំបាច់ព្រះពុទ្ធសាសនាទេ?

លន់៖ បាទ ។

កុសល៖ ចឹងមកចេះវាកាន់តែល្អទៀតហើយដល់ឥឡូវណាស់ មិនមានលួចមិនប្លន់មិនអី?

លន់៖ មិនលួចមិនប្លន់ មិនបន្តក្តៅក្រហាយឲ្យគ្នា មិនបៀតបៀនគ្នា ។

កុសល៖ ចឹងដាក់កំរិតខ្ពស់ ។

លន់៖ សើច... ។

កុសល៖ ចឹងចំពោះការចូលរួមបំពេញកិច្ចការនៅក្នុងភូមិ តើប្រជាជនចូលរួមក្នុងការអនុវត្តនយោបាយភូមិឃុំដូចថា ដូចថាបងដាក់បញ្ហាទៅប្រជាជនសហការណ៍បានដល់កំរិតណាដែរ?

លន់៖ កន្លែងនេះខ្ញុំធ្វើទៅមានជំនឿចិត្តណាស់ ត្រង់កន្លែងដែលសហការណ៍នេះឯង ហើយរាល់វគ្គមានប្រជុំក្នុងការដែលខ្ញុំផ្សព្វផ្សាយអីផ្សេងៗ ខ្ញុំថាកំលាំងខ្ញុំ១៨៩គ្រួសារ ខ្ញុំហៅប្រជុំជាគោលការណ៍តាមដានរបស់ខ្ញុំទៅលើវគ្គមានណាស់ ។

កុសល៖ បាទ ។

លន់៖ ក្នុងរយៈប៉ុន្មានឆ្នាំនេះ គិតទៅនៅតែល្អប្រសើរនៅឡើយ ចង់និយាយថា ខ្ញុំប្រកាសឲ្យមួយគ្រួសារម្នាក់ អត់ណាស់ក៏ដាងមួយរយគ្រួសារដែលបានមកស្តាប់ការអប់រំណែនាំ មកទទួលផែនការតែម្តង ។

កុសល៖ ចឹងគុណភាពអនុវត្តបានខ្ពស់បងចឹង?

លន់៖ បាទ ។

កុសល៖ ចឹងដូចបងលើកឡើងពីមុនមកមានពាក់កណ្តាលទេ ដែលជាប្រជាជនក្នុងស្រុកសាមគ្គីគ្នាហាក់ដូចជាល្អ ចឹងអ្នកចំណូលថ្មីបងមានសង្កេតឃើញសហការគ្នារវាងប្រជាជនចាស់ប្រជាជនថ្មីបែបណាដែលបង?

លន់៖ នេះខ្ញុំចង់បញ្ជាបន្តិចដែរ ព្រោះថាចេះថា ខ្ញុំពិនិត្យមើលជាប្រពៃណី ឲ្យអ្នកភូមិខ្ញុំកាលពី៩៧គ្រួសារណាស់ ។

កុសល៖ បាទ ។

លន់៖ កំលាំង៤១០នាក់ កំលាំងហ្នឹងមានប្រពៃណីសាមគ្គីគ្នារហូតមកដល់សព្វថ្ងៃនេះ ទើបក្រោយឆ្នាំ២០០១ទេ មានកំលាំងចំណូលណាស់ មានលក្ខពីរយ៉ាងដែលខ្ញុំសម្គាល់បានសម្គាល់បានទី១ គេមករស់នៅជាមួយយើងនេះសម្របខ្លួនទៅតាមអ្នក៩៧គ្រួសារ ឯទី២ គេសម្របសម្រួលតែចំណែកណាទេ ឯចំណែកណាក៏មិនសូវល្អដែលណា ។

កុសល៖ បាទ ។

លន់៖ បើគិតទៅច្រើនបន្តបញ្ហាដែរ ។

កុសលៈ ឧទាហរណ៍បង?

លន់ៈ ជាការឈ្លោះប្រកែក ជាតវ៉ាទៅលើកន្លែងជម្លោះដែលមិនសមឈ្លោះ ដេរប្រចោលគ្នាទាក់ទងគងសម្តីផ្សេងៗ តែប៉ុណ្ណឹងទេ ។

កុសលៈ បាទ!ទាក់ទងដីធ្លី?

លន់ៈ រឿងដីរើងធីក៏គេបុិនក្តីដែរ មិនប្រកែកណាស់ ។

កុសលៈ បាទ ។

លន់ៈ តែរឿងខ្លះទៅគឺថា រើមិនរួចត្រង់ថា យើងអ្នកថ្មីដែរ តែដល់និយាយយកមែនទែនទៅអ្នកចាស់ៗគេរកសាក្សីចាញ់គេទៅ ។

កុសលៈ បាទ!ចឹងជាការពិតទេ បងរវាងប្រជាជនចាស់មានសាមគ្គីភាពល្អ?

លន់ៈ បាទ ។

កុសលៈ ដល់ពេលមានអ្នកថ្មីមកហាក់បីមានភាពតវ៉ា ភាពគំលាតគ្នានិងច្រើននៅក្នុងសង្គមមានជម្លោះបន្តិចបន្តួចនៅក្នុងសង្គម ។

លន់ៈ តែខ្ញុំបានបែកហើយថា វាមានមែនតែវាមិនមានចំនួនច្រើនណាស់ តែយើងគ្រាន់តែកំណត់ថាវាមានភាពខុសប្លែកតែប៉ុណ្ណឹងទេ ។

កុសលៈ វាខុសផ្លែក តែវាអាចមានជម្លោះជាមួយសង្គម គំលាតសង្គមដែលវាមានបញ្ហាធំទៅថ្ងៃក្រោយទេបង?

លន់ៈ ខ្ញុំគិតថា វាមិនអាចទេ បានថាមិនអាចពីព្រោះថា ក្រោមរបបន្រសង្គមវាមានច្បាប់ណាស់ទាក់ទងទៅការប្រព្រឹត្តិអាក្រក់អាហ្នឹងមិនដឹងធ្វើម៉េចទេ ទៅតាមផលអាក្រក់ទៅ ។

កុសលៈ ចឹងទាក់ទងទៅនិងបញ្ហាសីលធម៌ គោរពទៅតាមព្រះពុទ្ធសាសនាបងយល់ថា តើបងថាកន្លែងដូចថាបងមានការគោរពល្អណាស់?

លន់ៈ បេះចាំមើលខ្ញុំនិយាយបន្តិចណាស់ កាលនោះខ្ញុំគិតថា ខ្ញុំនៅក្រៅច្បាប់ណាស់ ភាគច្រើនអ្នកមានវិន័យសីលធម៌ គុណធម៌ណាស់ តែគ្រាន់តែខុសប្លែកបន្តិចនៅកន្លែងនេះត្រង់ដែលថា ក្រោយយើងមានវត្តមានអារាមហៅថា ជំនឿទៅលើសាសនាព្រះពុទ្ធណាស់ ។

កុសលៈ បាទ ។

លន់ៈ កំលាំងខ្ញុំវាមិនសូវ មិនសូវចូលរួមទៅខាងវត្តវ៉ា ។

កុសលៈ ចឹង?

លន់ៈ ខ្ញុំឆ្ងល់កន្លែងនេះ ។

កុសលៈ ចឹង?

លន់៖ បាទ! ហើយបើនិយាយពីភាពទំនាក់ទំនងហៅថា សាមគ្គីមានល្អណាស់ តែខាងវត្តមិនសូវមាន ។

កុសល៖ ចំណែកម្ទេះ?

លន់៖ ខ្ញុំវាចំណែកអាកន្លែងនេះ ។

កុសល៖ ខ្ញុំសួរចាប់អារម្មណ៍ដែរ?

លន់៖ បាទ ។

កុសល៖ មិនសូវចូលរួមទៅវត្តទៅវ៉ា សាមគ្គីភាពគ្នាមាន ។

លន់៖ សាមគ្គីភាពនៅក្នុងភូមិល្អ តែពេលទៅវត្តទៅវ៉ាដូចជាមិនសូវមានតែខ្ញុំបានមើលហើយ ពីព្រោះពួកខ្ញុំនេះមិនសូវមានពួកចាស់ៗ ។

កុសល៖ បាទ ។

លន់៖ ចឹងអស់នៅ?

កុសល៖ នៅសុំបន្តបន្តិចទៀតបង?

លន់៖ បាទ ។

កុសល៖ ចឹងចំពោះចំណុចនេះខ្ញុំមិនសូវបានដឹងពីមុនមកដែលណាស់ ខ្ញុំដាក់ថា មិនសូវទៅវត្តទៅវ៉ា តែគាត់មានសីលធម៌ពីមុនមកល្អ?

លន់៖ បាទ! ចេះកន្លែងនេះខ្ញុំអាចបញ្ជាបាន វាទាក់ទងនិងចាស់ៗមិនសូវមានច្រើន ដល់មិនសូវមានទៅវាមិនសូវបានទទួលពីរឿងធម៌រឿងអារ្យណាស់ ។

កុសល៖ បាទ ។

លន់៖ មិនសូវយល់មិនសូវជ្រាបទៅ ក៏មិនសូវបានបំផុតដឹកនាំកូនក្នុងការធ្វើបុណ្យធ្វើទានវត្តអារាមនោះឲ្យបានគ្រប់គ្នាណាស់ ។

កុសល៖ បាទ ។

លន់៖ គ្រាន់តែប៉ុណ្ណឹងទេ ចំណុចដែលខ្ញុំមើលឃើញនោះ តែទាក់ទងទៅហ្នឹងកត្តាសាមគ្គីក្នុងភូមិអត់មានអីទេ សាមគ្គីគ្នាល្អណាស់ ។

កុសល៖ ចុះចំពោះរដ្ឋាភិបាលវិញ សំនួរថា តើរដ្ឋាភិបាលបានផ្តល់សន្តិសុខដល់ពូដល់បងក្រុមគ្រួសារបងដល់កំរិតណា មានតិចឬច្រើន?

លន់៖ សម្រាប់គ្រួសារខ្ញុំអត់មានបញ្ហាទេ ។

កុសល៖ ចឹងអាចថា ច្រើន អាចដាក់ថាច្រើន?

លន់៖ បាទ ។

កុសលៈ តើរដ្ឋាភិបាលបានផ្តល់ដល់សន្តិសុខដល់ស្រុកភូមិរបស់លោកបងដល់កំរិតណាដែរ?

លន់ៈ កន្លែងហ្នឹងដូចថា វាមិនបានមួយរយភាគរយទេ ។

កុសលៈ ចឹងខ្ញុំអាចដាក់ត្រឹម៨ឬ៩បងណាស់ ។

លន់ៈ បាទ ។

កុសលៈ បើសិនជាបងចង់បានបញ្ជាក់ថា មានខ្វះខាតអីទៀត ខ្វះខាតកន្លែងណាខ្លះ?

លន់ៈ ការខ្វះខាតបើគិតឲ្យដល់ទៅ វាខ្វះខាតខាងរដ្ឋាភិបាលវាមិនបានមកបំពេញឲ្យពួកខាងក្រោម ដូចជា ពួកប៉ូលីស ពួកសមត្ថកិច្ចអីគេបម្រើតួនាទីឲ្យបានត្រឹមត្រូវ ។

កុសលៈ ខ្ញុំក៏សង្កេតឃើញចឹងដែរ ចឹងសមត្ថកិច្ចមានការខ្វះខាត?

លន់ៈ បាទ ។

កុសលៈ ជាពិសេសកងកំលាំងប្រដាប់អាវុធ ខ្ញុំសង្កេតឃើញចឹងដែរ ការផ្សារគាត់ហាក់បីដូចជាមានច្រើន ចុះតើរដ្ឋាភិបាលបច្ចុប្បន្នមានបានបូជាបូរណភាពប្រទេសជាតិយើងដល់កំរិតណាតាមបងយល់ តាមជាក់ស្តែងយើងមាបបញ្ហាជាមួយប្រទេសជិតខាង?

លន់ៈ អាហ្នឹងខ្ញុំធ្លាប់តែនៅនេះជាប់និងព្រំដែនថៃណាស់ ។

កុសលៈ វាជាក់ស្តែង?

លន់ៈ រាជ្យរដ្ឋាភិបាលបានយកចិត្តទុក្ខដាក់យ៉ាងខ្លាំង ក្នុងការការពារបូរណភាពទឹកដីបានយកចិត្តទុកដាក់ចាប់អារម្មណ៍ ខ្ញុំគិតថាខ្លាំងមហិមាហើយ ។

កុសលៈ ចុះលើប្រពន្ធ័យុត្តិធម៌វិញ បងយល់ថាតើប្រពន្ធ័យុត្តិធម៌ស្រុកយើងហ្នឹងមានយុត្តិធម៌ដល់កំរិណាដែរ?

លន់ៈ សម្រាប់នៅក្នុងស្រុករបស់យើងនេះ ខ្ញុំគិតថា មិនទាន់គ្រប់គ្រាន់នៅឡើយទេ ។

កុសលៈ ចឹងពី១ដល់៩គឺ១តិច៩ច្រើនបំផុតបងឲ្យលេខប៉ុន្មាន បើ៧វាឡើងទៅលើហើយ ។

លន់ៈ ខ្ញុំមិនអាចចេះកំណត់បានទេ ។

កុសលៈ ចឹងវាមាននៅក្នុងការខ្វះខាត?

លន់ៈ បាទ ។

កុសលៈ ខ្ញុំសរសេរដាក់ថា ការខ្វះខាតចុះ ។

លន់ៈ បាទ ។

កុសលៈ ចឹងបងជឿទៅលើអាជ្ញាធរមូលដ្ឋានទៅដល់កំរិតណា មានន័យថាកំរិតថ្នាក់ឃុំ កំរិតស្រុកថ្នាក់ខេត្ត?

លន់ៈ មិនមានជំនឿមួយរយភាគរយទេ ។

កុសលៈ ដោយសារថាមានការខ្វះខាតច្រើន?

លន់ៈ បាទ!ខ្ញុំគិតថា វាមិនមានជំនឿមួយរយភាគរយតែប៉ុណ្ណឹងទេ ។

កុសលៈ ចឹងចំពោះបងផ្ទាល់វិញ បងយល់ថា ការគោរពគោលនយោបាយរបស់រដ្ឋាភិបាលឡូដល់កំរិតណាដែលបងពី១ដល់៥ ?

លន់ៈ ខ្ញុំគិតថា វាស្មើរ៥ទៅហើយ ។

កុសលៈ ៥ចុះ?

លន់ៈ បាទ ។

កុសលៈ អស់ពីចិត្ត?

លន់ៈ អតស់ពីចិត្តពីថ្ងៃមហើយ ។

កុសលៈ តើបងមានលក្ខខ័ណ្ឌឲ្យមានកំរិតនៅក្នុងចំណុចណាមួយ សំនួរសួរថាបងយល់ស្របជាមួយរដ្ឋាភិបាលដល់កំរិតណាដែរ មានលក្ខខ័ណ្ឌដែលឬទេ?

លន់ៈ ខ្ញុំគិតថា ខ្ញុំជាមួយរដ្ឋាភិបាលមិនមានលក្ខខ័ណ្ឌអីទេ គិតដោយអត់មានលក្ខខ័ណ្ឌតែម្តង ការជឿជាក់ជាមួយរដ្ឋាភិបាលហ្នឹង ទាំងបម្រើការងារ តាំងជំនឿចិត្តគិតថា អត់មានលក្ខខ័ណ្ឌទេ ។

កុសលៈ ចឹងខ្ញុំចង់សួរត្រឡប់ ឥឡូវនេះចប់រឿងរដ្ឋាភិបាល ខ្ញុំចង់សួរមួយកន្ទាកទៀតទាក់ទងទៅនិងដូចការគិតរបស់បងទៅលើអតីតកាល ទៅលើរបបខ្មែរក្រហមណាស់ សួរឧបមាថា តើអ្នកដែលធ្វើតាមបញ្ជាគេជំនាន់ហ្នឹង ពីព្រោះថា បងជឿថា តើគេធ្វើហ្នឹងជឿទៅលើបងផ្ទាល់ជំនាន់ហ្នឹង ថាតើគេធ្វើទៅតាមមាគ៌ាបដិវត្តរបស់អង្គការ គេយល់ថាត្រឹមត្រូវឬមួយយើងយល់តាមគេ?

លន់ៈ បើនិយាយត្រឡប់ទៅកាលសម័យនោះខ្ញុំគិតថា ការដែលយើងជឿណាស់ ទី១ជឿដែលវាផុសចេញពីគេហៅថា ប្រាជ្ញាគិតពិចារណាបានចេញទៅជាហេតុផលណាស់ តែយើងគួរតែទទួលបាន ទាល់តែយើងមានសំនួរ តែសម្រាប់ខ្ញុំកាលពីសម័យនោះមិនដែលមានជំនឿអីទេ អត់មានជំនឿចិត្តអីទាំងអស់ ។

កុសលៈ បាទ ។

លន់ៈ ទៅលើដឹកនាំណាក៏ខ្ញុំមិនដែលមានជំនឿដែល ប៉ុន្តែគ្រាន់ថា ក្នុងរបបនៃសង្គមយើងធ្វើអ្វីកើតមានតែសន្សំខ្លួនថាឲ្យរស់ទៅ ទំរាំតែមានឱកាសតែប៉ុណ្ណោះទេ ។

កុសលៈ ធ្វើដើម្បីរស់?

លន់ៈ បាទ ។

កុសលៈ ចឹងក្នុងនាមជាជនបដិវត្តល្អម្នាក់ បងយល់ថាក្នុងជំនាន់នោះ តើយើងយល់ថា សង្គមហ្នឹង ធ្វើឲ្យមានឲ្យប្រទេសជាតិយើងរឹងមាំនិងជាគំរូដល់ពិភពលោក តើបងជឿទេ ជឿថា ប្រទេសធ្វើទៅប្រទេសសង្គមនិយមនិងក្លាយទៅជាប្រទេសមួយដែលមានលក្ខណៈរឹងមាំការ ពារបូរណភាពដែនដីបាន?

លន់ៈ ខ្ញុំអត់ជឿទេ ។

កុសលៈ ចឹងបងអត់ជឿទេ?

លន់ៈ បាទ ។

កុសលៈ ហេតុអីបានជាបងអត់ជឿពេលហ្នឹង?

លន់ៈ ពីព្រោះថា រឿងវែងឆ្ងាយណាស់ ។

កុសលៈ បានន័នាំប្អូនៗជំនាន់ក្រោយឲ្យបានដឹងផង?

លន់ៈ មិនអាចធ្វើទៅរួច មិនអាចធ្វើទៅកើត ពីព្រោះថា ប្រទេសយើងវាក្រីក្រណាស់ ។

កុសលៈ បាទ!ក្រីក្រ ។

លន់ៈ ខ្វះធនធានមនុស្សទាំងស្រុងមានអីណា សូម្បីតែរបបដឹកនាំសម័យនោះយើងគិតមើលថា ភាគច្រើនសុទ្ធតែពួកអ្នកល្ងង់មកដឹកនាំ ដល់ចឹងទៅមានអី មានតែធ្វើម៉េចឲ្យតែខូចទៅ ។

កុសលៈ ចឹងបងធ្វើទៅតាមគេពេលហ្នឹង ដោយសារយើងគិតថាធ្វើម៉េចឲ្យតែម៉ារស់?

លន់ៈ បាទ ។

កុសលៈ គ្រួសារយើងរួចផុតពីគ្រោះភ័យ ។

លន់ៈ ធ្វើម៉េចឲ្យតែខ្លួនបានរស់មានជីវិតមក ទំរាំយើងមានឱកាស ។

កុសលៈ ចឹងត្រឡប់មករដ្ឋាភិបាលបច្ចុប្បន្នហ្នឹងទៀត អ្វីទៅដែលបងចង់បានបំផុតពីរដ្ឋាភិបាល របប នេះឃើញថា ទី១ អាចប្រកបរបរមានជីវភាពរស់នៅល្អនិងមានសុវត្ថភាព?

លន់ៈ ខ្ញុំក្រោយពីបានធ្វើសមាហរណ៍កម្មហើយ ខ្ញុំគិតថាខ្ញុំមានសិទ្ធមានសេរីភាពក្នុងការប្រកបរបរ រកស៊ីចិញ្ចឹមជីវិតជាពិសេសក្នុងការដើរហើយស្នាក់អាស្រ័យ និយាយរួមផ្នែកការរកស៊ី ទំនាក់ទំនងអីផ្សេងៗជាមួយបងប្អូនអ្នកស្រុកអ្នកភូមិឬក៏មិត្តភក្តិជិតឆ្ងាយអីណាស់ ទាំងក្នុង ទាំងក្រៅអីទៅតាមលទ្ធភាពខ្ញុំមាន នេះហើយជាឱកាសនិងលក្ខណៈឲ្យខ្ញុំខំពង្រីកការទំនាក់ ទំនងជាមួយមិត្តភក្តិជិតឆ្ងាយណាស់ ។

កុសលៈ បាទ ។

លន់ៈ ព្រោះយល់ឃើញថា វាជាសិទ្ធសេរីភាពទៅហើយ ។

កុសលៈ ចឹងមានសិទ្ធសេរីភាព?

លន់៖ ហ្នឹងហើយធំគឺសិទ្ធសេរីភាព ។

កុសល៖ ចឹងបងយល់ថា ការគ្រប់គ្រងរដ្ឋាភិបាលបច្ចុប្បន្នហ្នឹងថា អាចផ្តល់នៅការគ្រប់គ្រងនិងស្ថេរភាពពេញលេញដល់កំរិតណាដែរ?

លន់៖ កន្លែងខ្ញុំដូចថាមិនអាចកំណត់បាន ។

កុសល៖ មិនអីទេ ។

លន់៖ តែក៏ខ្ញុំជឿជាក់បានដែរ ។

កុសល៖ ជឿជាក់ហើយវានៅមានកំរិត?

លន់៖ ហ្នឹងហើយវានៅមានកំរិត ។

កុសល៖ ចឹងបងគាំទ្រឲ្យរដ្ឋាភិបាលកាត់បន្ថយជនបរទេសដែលទេ?

លន់៖ កន្លែងហ្នឹងជាការពេញចិត្តរបស់ខ្ញុំ ឲ្យរាជ្យរដ្ឋាភិបាលកាត់បន្ថយឬថាធ្វើច្បាប់សម្រាប់ពួកអន្តោប្រវេសអីណា ។

កុសល៖ បាទ ។

លន់៖ កុំឲ្យវាហៀចូលមកខ្លាំងពេក ។

កុសល៖ ចឹងជនបរទេសណាខ្លះដែលគិតថា មានបញ្ហានៅក្នុងស្រុកភូមិយើងហ្នឹង?

លន់៖ ខ្ញុំថា នៅក្នុងស្រុកយើងហ្នឹងគ្មានពីណាក្រៅពីជនជាតិវៀតណាមទេ ។

កុសល៖ នៅនេះមានច្រើនបង?

លន់៖ នៅនេះមិនសូវមានប៉ុន្មានទេ ។

កុសល៖ ចឹងប្រយ័ត្នបំផុតរឿងវៀតណាមចឹងរឿងថៃបង?

លន់៖ រឿងថៃនោះវាមិនមានហូរចូលមកយើងទេ ។

កុសល៖ ចឹងអត់មានទេ?

លន់៖ បាទ ។

កុសល៖ ចឹងមានតែវៀតណាម?

លន់៖ បាទ ។

កុសល៖ គេមករកស៊ី?

លន់៖ គេមកបែបណាយើងអត់យល់ ។

កុសល៖ ចុះជនជាតិចិន?

លន់៖ អាហ្នឹងជាផ្នែកមួយនៃអ្នករកស៊ីដូចជាមិនអីទេ ។

កុសល៖ ចឹងមិនមានបញ្ហាទេ?

លន់៖ បាទ!ម្យ៉ាងទៀតវាឆ្លងប្រទេសវាមិនងាយបន្តអីទេ ។

កុសល៖ ត្រូវហើយ ចឹងបងជឿថា គោលបំណងនៃការបង្កើតច្បាប់កុំប្រជាជនប្រកបបទខុក្រិដ្ឋពី១ ដល់៩បងជឿដល់កំរិតណា?

លន់៖ ខ្ញុំថា ប្រទេសកម្ពុជាយើងត្រូវតែមានច្បាប់ល្អប្រសើរ តែគ្រាន់ថាច្បាប់នោះមិនទាន់និង ត្រូវឲ្យអ្នកគោរពច្បាប់នៅធ្វើទៅតាមច្បាប់មិនទាន់បានត្រឹមត្រូវល្អណាស់ វាពិបាកដែលកន្លែងហ្នឹង ខ្ញុំក៏មិនអាចកំណត់បានដែរ ។

កុសល៖ បាទ ។

លន់៖ ពីព្រោះថា បើសម្រាប់ឲ្យអ្នកគោរពដូចយ៉ាងខ្ញុំ ពួកអ្នកស្រុកជាអ្នកគោរព តែអ្នកអនុវត្ត ច្បាប់នោះវាលំបាកដែរ ។

កុសល៖ សំនួរមួយទៀតវាទាក់ទងនិងរបបខ្មែរក្រហមហើយហ្នឹងមកដល់រដ្ឋាភិបាលទៀតណាស់បង?

លន់៖ បាទ ។

កុសល៖ ខ្ញុំសួរប្រជាជនកម្ពុជាដែលល្អមួយរូបដែលមកពីគ្រួសារកសិករជាជនបដិវត្តដ៏ពិតប្រាកដនិង ជាជនស្នេហាជាតិមានហ៊ានពលីជីវិតហ៊ានប្រឆាំងនិងជនបរទេសទាំងឡាយ ចឹងក្នុងសំនួរនេះ សួរថា តើប្រជាជនកម្ពុជាម្នាក់ត្រូវមានគុណសម្បត្តិបែបណា?

លន់៖ កន្លែងនេះដូចជាពិបាកនិយាយណាស់ ។

កុសល៖ បងអត់ឆ្លើយក៏បានដែលអត់អីទេ បើពិបាកឆ្លើយ ទាក់ទងនិងស្នេហាជាតិស្រឡាញ់ជាតិ?

លន់៖ បាទ!ខ្ញុំមិនដឹងសួរថាឆ្លើយយ៉ាងម៉េច បើនិយាយកាលពីសម័យនេះហ្នឹងនិយាយតែពីស្នេហា ជាតិហ្នឹង និយាយពីរឿងសីលធម៌គុណធម៌ តែចុងក្រោយយើងទប់ខ្លួនយើងយ៉ាងម៉េចឲ្យ តែជីវិតយើងបានរស់ ។

កុសល៖ ត្រូវហើយ ។

លន់៖ យើងមិនអាចនិយាយបាន ។

កុសល៖ ចឹងបងគិតថា ជំនាន់នោះប្រជាជនល្អមួយរូបគឺជាពលរដ្ឋដែលស្មោះត្រង់និងអង្គការ?

លន់៖ ស្មោះត្រង់ ។

កុសល៖ អនុវត្តគោលនយោបាយរបស់អង្គការដោយអត់ខ្ចោះចឹងបង តើបងយល់ដល់កំរិតណា ដែរ ក្នុងជំនាន់នោះ?

លន់៖ មិនអាចនិយាយបានទេ ។

កុសលៈ បាទ!កម្ពុជាល្អមួយរូបគឺជាប្រជាជនដែលគិតពីផលប្រយោជន៍ផ្ទាល់ខ្លួន ហ៊ានលះបង់ទ្រព្យសម្បត្តិនិងប្រឹងប្រែងធ្វើការដើម្បីផលប្រយោជន៍សមូលហភាព យល់ដល់កំរិតណាដែលពី១ដល់៥?

លន់ៈ ខ្ញុំគិតថា មកដល់បច្ចុប្បន្ននេះស្រុកភូមិរបស់ខ្ញុំគឺថា មានបន្តរហើយ ។

កុសលៈ ច្រើនបងណាស់សមូលហភាព?

លន់ៈ បាទ ។

កុសលៈ គាំទ្រនិងគោរពអង្គការជានិច្ចនិងប្រត្តិតាមមាគ៌ាបក្សយ៉ាងម៉ឺងម៉ាតជំនាន់នោះ តើបងគាំទ្រនិងវិន័យរបស់អង្គការខ្មែរក្រហមជំនាន់នោះដែលទេ?

លន់ៈ គោរពតាមគេ ។

កុសលៈ ខ្លាចគេណាស់?

លន់ៈ ខ្លាចគេ ។

កុសលៈ ចឹងខ្លាចអង្គការខ្មែរក្រហមចឹងខ្ញុំដាក់ចឹងបានគោរពខ្លាច ។

លន់ៈ បាទ ។

កុសលៈ ឥឡូវឆ្លងមករដ្ឋាភិបាលបច្ចុប្បន្នណាបង បងគិតថាប្រជាជនយើងសព្វថ្ងៃជាប្រជាជនគំរូម្នាក់គួរតែដូចថា ហ៊ានលះបង់ពលីជីវិតដើម្បីការពារបូរណភាពទឹកដីនិងអត្តសញ្ញាណជាតិបានដល់កំរិតណា ពី១ដល់៥?

លន់ៈ ខ្ញុំគិតថាបេះ នៅភូមិខ្ញុំសព្វថ្ងៃនេះ មានភាគច្រើនណាស់ហ៊ានលះបង់អាយុជីវិតដើម្បីការពារជាតិ?

កុសលៈ ចឹងមានតាំងពីមុនមកហើយ?

លន់ៈ បាទ ។

កុសលៈ សំនួរនេះបងឆ្លើយមកបានក្បោះក្បាយខ្ញុំអរគុណបងមែនទែនហើយ ។

លន់ៈ បាទ ។

កុសលៈ ចឹងប្រជាជនមួយរូបជាមនុស្សដែលត្រៀមខ្លួនជាស្រេចដើម្បីអនុវត្តគោលនយោបាយរដ្ឋាភិបាល ច្រើន ធ្វើជាប្រជាពលរដ្ឋមួយរូបត្រូវតែធ្វើតាមរដ្ឋាភិបាលអនុវត្តគោល?

លន់ៈ មានច្រើន ។

កុសលៈ ខ្ញុំមានអារម្មណ៍ថា យើងមានកាតព្វកិច្ចត្រូវគាំទ្ររដ្ឋាភិបាលបើទោះបីខ្ញុំមិនយល់ស្របក៏ដោយ ចុះបើសិនជាគោលនយោបាយរដ្ឋាភិបាលដាក់មកវាខុសនិងចិត្តបង តើបងយល់យ៉ាងណាដែរ?

លន់៖ ហ្នឹងវាទាក់ទងហ្នឹងហេតុផល ។

កុសល៖ ហេតុផលដែលមាន ហ៊ានចេញមុខរិះគន់ទេ?

លន់៖ ហ៊ានចេញមុខរិះគន់តវ៉ារិះគន់ជាធម្មតាណាស់ ។

កុសល៖ បាទ ។

លន់៖ បើយល់ឃើញថាត្រូវយើងឯកភាពទៅណាស់ ។

កុសល៖ តែបើខុសប្រាប់ថាខុសចឹងតែម្ដង?

លន់៖ បើខុសឆ្លើយថាខុសតែម្ដង ។

កុសល៖ ប្រជាជនល្អមួយរូបគឺប្រជាជនដែលតែងតែគោរពច្បាប់អាជ្ញាធរសមត្ថកិច្ចឲ្យបានជាប់ខ្លួន ចឹងបងយល់ថា ចម្លើយនេះជាចម្លើយត្រឹមត្រូវទេ?

លន់៖ បាទ ។

កុសល៖ បើសិនជាប្រទេសថៃឈ្លានពានដណ្ដើមប្រាសាទព្រះវិហារតើបងហ៊ានស្ម័គ្រចិត្តឲ្យកូនចៅទៅការពារជាតិបានដល់កំរិតណា?

លន់៖ សម្រាប់ខ្ញុំនេះបើវាទាក់ទងទៅនិងការឈ្លានពាន មិនត្រឹមថាកូនទេខ្ញុំក៏ទៅដែរ ។

កុសល៖ ចឹងកំរិតខ្ពស់ ចឹងខ្ញុំដាក់ខ្ពស់ ។

លន់៖ បាទ ។

កុសល៖ ខ្ញុំហ្នឹងធ្វើអ្វីៗទាំងអស់ដែលរដ្ឋាភិបាលដាក់បញ្ជា?

លន់៖ បាទ ។

កុសល៖ ក្នុងនាមជាជនស្នេហាជាតិម្នាក់ខ្ញុំនិងប្រយុទ្ធប្រឆាំងដើម្បីការពារប្រសាទនេះ មិនបាច់ឆ្លើយទេបងឆ្លើយហើយមិញ ខ្ញុំនិងគវ៉ាបើសិនជារដ្ឋាភិបាលមិនអាចការពារប្រាសាទព្រះវិហារបាន?

លន់៖ បាទ ។

កុសល៖ ឧទាហរណ៍កាតព្វកិច្ចផ្សេងៗនិងកាតព្វកិច្ចយោធា ចំណុចប្រសើរបំផុតដែលប្រជាជនម្នាក់អាចធ្វើបាននោះ គឺគាំទ្ររដ្ឋាភិបាលយ៉ាងពេញទំហឹងក្នុងនាមជាយោធា មានច្រើនទេ?

លន់៖ មានច្រើន ។

កុសល៖ ច្បាប់គឺជាសមាភាពសំខាន់បំផុតសម្រាប់ប្រទេសមួយ បងនិយាយហើយ ។

លន់៖ បាទ ។

កុសល៖ ប្រជាពលរដ្ឋទាំងអស់គួរតែបំពេញកាតព្វកិច្ចដូចគ្នាដើម្បីឲ្យប្រទេសជឿនលឿនទៅមុខ?

លន់៖ បាទ ។

កុសលៈ នេះទាក់ទងនិងការស្វែងយល់ពីស្មារតីមួយគឺថាតិចតួច ដូចខ្ញុំនិយាយពីមុនហ្នឹងបង?

លន់ៈ បាទ ។

កុសលៈ ត្រូវខ្លាំងណាស់ ខ្ញុំគិតថាខ្ញុំមានករណីកិច្ចធ្វើការងារដែលចាំបាច់ត្រូវធ្វើបើសិនជារដ្ឋាភិបាលធ្វើអ្វីមួយដែលប្រឆាំងនិងគោលការណ៍សីលធម៌របស់ខ្ញុំ ពី១ដល់៥ ចឹង៥បងណាស់ ។

លន់ៈ បាទ ។

កុសលៈ ខ្ញុំនិងប្រឆាំងបើសិនជារដ្ឋាភិបាលរំលោភបំពារបំពានសិទ្ធជាមូលដ្ឋានរបស់ខ្ញុំ ។

លន់ៈ បាទ ។

កុសលៈ ខ្ញុំនិងប្រឆាំងដាច់ខាតបើសិនជារដ្ឋាភិបាលបំពារបំពានទៅលើសិទ្ធមនុស្សក្នុងស្រុកភូមិខ្ញុំ?

លន់ៈ បាទ ។

កុសលៈ បងជាអ្នកស្នេហាជាតិម្នាក់ច្បាស់ ការវាយតម្លៃពីសត្តិអារម្មណ៍និងផលប្រយោជន៍របស់បុគ្គដែលតភ្ជាប់ទៅនិងតុលាការទាក់ទងទៅនិងសន្តិភាពដូចជាការផ្សះផ្សារ ។

លន់ៈ បាទ ។

កុសលៈ ចំណុចទីពីរទាក់ទងនិងការផ្សះផ្សារដូចជាបងដឹងស្រាប់ហើយរដ្ឋាភិបាលបានបញ្ជាថា យើងមិនឲ្យមាន០ ០ ៣ទៀតទេ ។

លន់ៈ បាទ! ត្រូវហើយ ។

កុសលៈ ព្រោះថា ហេតុអីយើងចង់បានសន្តិភាពយើងមិនឲ្យមានការប្របូកប្រេបល់ទៀតទេ នេះជាគោលជំហររបស់រដ្ឋាភិបាលណាស់បង?

លន់ៈ បាទ ។

កុសលៈ ចឹងដឹងថា តើបងគាំទ្របុឲ្យយោបល់យ៉ាងណាដែរ ចំពោះបញ្ហានេះ ។

លន់ៈ បាទ ។

កុសលៈ ឧទាហរណ៍មួយ អ្វីខ្ញុំសូមឲ្យបងរៀបរាប់ទាក់ទងមុននិងខ្ញុំសួរសំនួរឲ្យបងរៀបរាប់ពីការយល់ឃើញយ៉ាងណាធ្វើឲ្យប្រទេសយើងមានការផ្សះផ្សារជាតិ មានសន្តិភាពជារៀងរហូត ចំណុចនេះសំខាន់ណាស់បង សូមបងបញ្ជាក់ឲ្យច្បាស់លាស់?

លន់ៈ ខ្ញុំគិតថា វែងឆ្ងាយណាស់បើគិតទៅ តែបើណាណាជា ។

កុសលៈ ខ្ញុំសូមកាត់ប្រសាសន៍បង ខ្ញុំគិតថាបងដឹងច្រើនពីជំនាន់ហ្នឹង ក្នុងប្រវត្តិសាស្ត្រឲ្យកូនខ្មែរយើងរៀនឲ្យដឹងពីប្រវត្តិសាស្ត្រ តើប្រទេសយើងវាប្រេះស្រាំយ៉ាងណាអីយ៉ាងណាហើយ បងកុំឲ្យតែបរទេសភាគច្រើនបរទេស សម្រេចធ្វើចេះធ្វើចុះភាគច្រើន គេប្រកាសលុកលុយប្រទេសយើងពីសំណាក់បរទេស ខ្ញុំឯកភាពទាំងស្រុងវាធ្ងន់ណាស់ វាច្រើនណាស់បង

ការលុកលុយ ចឹងខ្ញុំចង់ដឹងបងប្អូនខ្មែរយើងជាពិសេសបងដែលឆ្លងកាត់ យើងធ្វើយ៉ាងណាដើម្បីឲ្យមានការផ្សះផ្សារជាតិ ដើម្បីឲ្យមានស្ថេរភាពសន្តិភាពទៅមុខ?

លន់: ខ្ញុំគិតថា ការកាត់ទោសមិនមែនជាការផ្សះផ្សារជាតិប៉ុន្មានទេ ហើយមិនមែនថា នយោបាយឬជាមធ្យោបាយប្រសើរប៉ុន្មានដែរ ។

កុសលៈ បាទ ។

លន់: ចឹងបានសេចក្ដីថា ខ្ញុំគាំទ្ររដ្ឋាភិបាលកុំឲ្យមានកាត់បន្តទៅទៀត ពីព្រោះថា ពិសោធន៍ប្រវត្តិសាស្ត្រយើងការកាត់ទោសគ្នានេះ ច្រើនមានតែរឿង ។

កុសលៈ ចុះបើបងយល់ថា ថាតុលាការហ្នឹងធ្វើនៅស្រុកខ្មែរយើង វាជាការល្អឬមួយជាការអាក្រក់បង?

លន់: ខ្ញុំមិនអាចនិយាយបានកន្លែងហ្នឹង បានថាមិនអាចនិយាយពីព្រោះខ្ញុំមិនសូវជ្រាបរឿងតុលាការហ្នឹងផង តែខ្ញុំគិតថា វាជារឿងល្អហើយដែលមានតុលាការណាស់ ។

កុសលៈ បាទ ។

លន់: វាជាជាងអត់កាលពីសម័យនោះ ។

កុសលៈ ចឹងបងនៅស្រុកភូមិយើងហ្នឹងមានដែលតុលាការគេចុះមក គឺការកំរិតយល់ដឹងពីតុលាការហ្នឹងកំរិតណាដែលបង?

លន់: ខាងស្រុកភូមិខ្ញុំហ្នឹងមិនដែលសូវឃើញមានតុលាការអីមកទេ ។

កុសលៈ ចឹងប្រជាជនមិនសូវដឹងឬ?

លន់: ហើយក៏មិនសូវបានជ្រាបអាដែងច្បាប់ប្រព័ន្ធតុលាការអីយ៉ាងម៉េច ។

កុសលៈ ចឹងអត់មានបានជ្រាបទេ?

លន់: បាទ ។

កុសលៈ ចឹងមិនសូវយល់ដឹងពីប្រពន្ធច្បាប់ហ្នឹង?

លន់: បាទ ។

កុសលៈ ហេតុអីបានចឹងបង?

លន់: ពីព្រោះថា វាមិនសូវមានការអប់រំនែនាំឬក៏បង្រៀនអីទៅណាស់ វាមានដែលម្ដងម៉ោយាមអី កាលដែលគេកាត់ទោសខ្មែរក្រហមមេដឹកនាំណាស់ គេឲ្យទៅទស្សនាដែលម្នាក់ពីរនាក់មួយភូមិទៅ បើថាឲ្យយល់ឲ្យអីនោះ គ្រាន់តែទៅឃើញមកវិញបណ្ដោយ ។

កុសលៈ ចឹងគិតថា បង្កើតតុលាការហ្នឹងឲ្យនៅស្រុកខ្មែរគឺជាបញ្ហាមួយប៉ះពាល់យ៉ាងណាខ្លះ?

លន់: តុលាការរាល់ថ្ងៃហ្នឹង?

កុសលៈ បាទ!វាមានផលប៉ះពាល់យ៉ាងណាខ្លះ តាមពូយល់?

លន់ៈ តុលាការខាងណា?

កុសលៈ តុលាការដែលកាត់ទោសមេដឹកនាំខ្មែរក្រហមបច្ចុប្បន្នហ្នឹងណាស់ គេមិនបង្កើតនៅភ្នំពេញបង?

លន់ៈ បាទ ។

កុសលៈ តើបងយល់ថា វាប៉ះពាល់ដល់ការផ្សះផ្សារជាតិហ្នឹងយ៉ាងម៉េចខ្លះ?

លន់ៈ កន្លែងនេះដូចជាពិបាកនិយាយណាស់ ខ្ញុំមិនចេះនិយាយទេ ។

កុសលៈ ចុះបងយល់ថា និងធ្វើឲ្យប្រទេសយើងមានប្រព័ន្ធតុលាការ ខ្លះគេថាមានតុលាការហ្នឹងទៅប្រព័ន្ធច្បាប់ស្រុកយើងហ្នឹងវាល្អ?

លន់ៈ ខ្ញុំគិតថាចេះដែរ ដូចខ្ញុំបាននិយាយពីខាងត្បូងនោះណាស់ ខ្ញុំគិតរឿងតុលាការក៏ជារឿងល្អដែលណាស់ តែបើនិយាយថា ការកាត់ទោសបន្តគឺវាមិនល្អ ។

កុសលៈ បាទ!តែប៉ុណ្ណឹងទេ ចឹងការកាត់ទោសបន្តមិនល្អ?

លន់ៈ បាទ ។

កុសលៈ ចឹងទាក់ទងនិងបញ្ហាផ្លូវច្បាប់ គេថាបើសិនជាមានតុលាការទៅដូចជាបង្រៀនឲ្យក្មេងហ្នឹងចេះប្រព័ន្ធច្បាប់ទៅខាងមុខ បងជឿថា តុលាការហ្នឹងមានជះឥទ្ធិពលបែបហ្នឹងដែលទេ?

លន់ៈ ខ្ញុំគិតថា បើសិនជាមានបែបចឹងខ្ញុំគិតថា វាជារឿងល្អដែលបានសេចក្តីថា បើយើងមានច្បាប់ណាស់ ការអនុវត្តច្បាប់យើងឲ្យក្លាយទៅជានិតិរដ្ឋខ្ញុំគិតថា ខ្ញុំថារឿងល្អ ។

កុសលៈ តើបងគិតថា តុលាការហ្នឹងមានតួនាទីមានសារសំខាន់ការពារកុំឲ្យមេដឹកនាំស្រុកយើងទៅអនាគតហ្នឹង កុំឲ្យមានប្រព្រឹត្តអំពើកុំឲ្យឆ្លងកាត់របបដែលយើងឆ្លងកាត់មកទៀត?

លន់ៈ ខ្ញុំចង់បានណាស់អារឿងហ្នឹង ។

កុសលៈ បាទ!អរគុណខ្ញុំជឿថា សាលាក្តីនេះផ្តល់ឲ្យប្រជាជនកម្ពុជាទទួលនៅ យុត្តិធម៌មួយទាំងសងខាងតិចឬច្រើនបង?

លន់ៈ សើច.... ។

កុសលៈ សុទ្ធតែគ្មានឯងទេ ព្រោះទាក់ទងនិងការផ្សះផ្សារបងនេះណាស់ ។

លន់ៈ បាទ!សើច... ។

កុសលៈ ខ្ញុំចូលចិត្តបងឯងបងឯងសើចចឹង បើតាមបងនិយាយមកវាតិច ។

លន់ៈ នោះហើយ ។

កុសលៈ បងឆ្លើយហើយគ្រាន់តែខ្ញុំចង់បញ្ជាក់អ្វីដែលខ្ញុំពេញចិត្តចំពោះតុលាការហ្នឹង តុលាការហ្នឹងមានចៅក្រមជាជនជាតិខ្មែរផងដែរ ដូចជាមានបរទេសផងមានខ្មែរផង?

លន់ៈ មានខ្មែរផងមានបរទេសផង ។

កុសលៈ ចឹងបងចង់ឲ្យបរទេសសុទ្ធឬចង់ឲ្យខ្មែរសុទ្ធ?

លន់ៈ ខ្ញុំគិតថា មានខ្មែរយើងសុទ្ធវាយ៉ាងម៉េច វាមិនល្អទេឬមួយវាយ៉ាងណា?

កុសលៈ ចឹងបានថា ខ្ញុំឆ្ងល់ដែរ បានជាខ្ញុំសួរបងឯងហ្នឹង?

លន់ៈ ខ្ញុំឆ្ងល់ដូចតែគ្នាព្រោះខ្ញុំ ខ្ញុំតែងតែពិចារណាដែរ ចុះបើសិនជាខ្មែរយើងសុទ្ធទៅវាមិនអីឯករាជ្យប៉ុណ្ណាទៅឬក៏មិនអាចកាត់គេនោះបាន កន្លែងនេះដូចជាឆ្ងល់ដែលហ្នឹង មានតុលាការខ្មែរឯករាជ្យទៅមើល ។

កុសលៈ ចឹងឲ្យខ្មែរឯករាជ្យវាល្អជាង?

លន់ៈ វាល្អជាងហ្នឹងហើយ ។

កុសលៈ ល្អដែលចម្លើយហ្នឹង ចឹងបងឆ្លើយសំនួរនេះហើយចឹងមានសមាភាពអន្តរជាតិជាការល្អឬឲ្យមានភាពច្របូកច្របល់ទៅវិញ?

លន់ៈ ខាងតុលាការហ្នឹង?

កុសលៈ បាទ ។

លន់ៈ ខ្ញុំសង្ស័យមានខាងគេចូលចេះតែបន្តកាត់សើច...ព្រោះយើងពិសោធន៍កន្លងទៅមិនជាល្អប៉ុន្មានដែលទេ ។

កុសលៈ ចឹងបងចង់និយាយថា វាប៉ះពាល់ទៅដល់ការផ្សះផ្សារជាតិ ។

លន់ៈ ហ្នឹងហើយវាប៉ះពាល់ហើយ ។

កុសលៈ បងឆ្លើយហើយតុលាការហ្នឹងវាអាចមានលទ្ធភាពធ្វើឲ្យច្បាប់ក្លាយទៅជានិតិរដ្ឋគំរូ ចឹងសូមកាត់ប្រសាសន៍បងរៀនដល់កំរិតណាដែរ និយាយមកដូចជាអ្នកចេះដឹងម្នាក់?

លន់ៈ បើនិយាយពីកំរិតវប្បធម៌ខ្ញុំអត់មានថ្នាក់ដាក់និងគេទេ អត់មានបានរៀនអីទេ កាលខ្ញុំរៀននោះរៀនក្រោមម្លប់ស្វាយ មានអ្នករៀនមានអ្នកយាម យាមនោះមានយាមអីយាមកប៉ាល់ហោះ សម័យខ្ញុំរៀនណាស់ ។

កុសលៈ បាទ ។

លន់ៈ កប៉ាល់ហោះនោះយាមចេះទេ បើឃើញឲ្យមកប្រាប់គ្នាដើម្បីរកកន្លែងក្រាប ខ្លាចជិនាន់ពួកប៥២ចាក់នោះ ។

កុសលៈ ត្រូវហើយពួកអាកាំងពួកអាមេរិច?

លន់ៈ បាទ!ជំនាន់អាមេរិចហ្នឹង ដល់ចឹងមានសាលារៀនតែក្រោមដើមស្វាយក្រោមដើមឈើ ។

កុសលៈ បងអានដាច់និយាយបានទាំងអស់ ព្រោះបងប្រើពាក្យធ្ងន់ដូចជាពាក្យនិតិរដ្ឋអី ពាក្យអស់ហ្នឹងសុទ្ធតែជាពាក្យកំរិតពាក្យវប្បធម៌?

លន់ៈ វាចេះទេ កាលដែលចេះនេះ ចេះរៀនកាលពីសម័យគុណធម៌សីលធម៌សម័យខ្មែរក្រហម គេបង្រៀនពីគុណធម៌សីលធម៌និយាយតែប៉ុណ្ណឹង និយាយកងទ័ពមានវិន័យកងទ័ពមានសីលធម៌កងទ័ពមានគុណធម៌ កងទ័ពចេះឈឺចាប់ជាមួយអ្នកស្រុកចេះត្រូវទទួលការឈឺចាប់ពីអំពើចេះតែថាទៅសើច...ចេះតែប៉ុណ្ណឹងទេ ពាក្យមួយចំនួនក៏ខ្ញុំចេះដែរ ខ្ញុំបានសិក្សាក្រោយនេះទេ មើលសៀវភៅអីខ្លះ ។

កុសលៈ ចឹងខ្ញុំសុំសួរបន្ថែមបងណាស់?

លន់ៈ បាទ ។

កុសលៈ ដើម្បីសន្តិភាពខ្ញុំឯកភាពជាមួយទស្សនៈដែលថា កុំឲ្យមានការកាត់ក្តីលើសពីសំណុំរឿង ០០២ដូច?

លន់ៈ បាទ ។

កុសលៈ ក្នុងនាមជាប្រជាជនម្នាក់ខ្ញុំមានមរណៈភាពចំពោះសមត្ថផលកំពង់សម្រេចបានដោយតុលាការនេះបានដល់កំរិតណាបង តុលាការហ្នឹងអាចសម្រេចសមត្ថផលដល់កំរិតណាដែរ តិចតួចឬច្រើនក្នុងការផ្សះផ្សារជាតិ?

លន់ៈ ក្នុងការផ្សះផ្សារជាតិកុំឲ្យមានតទៅទៀតកុំឲ្យមានការកាត់ក្តី ។

កុសលៈ បាទ!កាត់ត្រឹមប៉ុណ្ណឹងឬយ៉ាងម៉េច?

លន់ៈ ខ្ញុំគិតបើសិនណាកាត់ត្រឹមប៉ុណ្ណឹងល្អមែនទែន បើសិនមិនឲ្យមានតទៅទៀតល្អច្រើន ។

កុសលៈ ប្រជាជនកម្ពុជាដែលមានមន្ទិលសង្ស័យចំពោះតុលាការមិនអាចចូលរួមផ្សះផ្សារជាតិនោះឡើយ ចង់និយាយថា អ្នកណាដែលមិនជឿទៅលើតុលាការហ្នឹងគឺថាយើងមិនអាចនាំឲ្យមានការផ្សះផ្សារជាតិបានទេ បើសិនយើងមិនជឿទៅលើតុលាការហ្នឹង យើងមិនអាចមានការផ្សះផ្សារជាតិ?

លន់ៈ បាទ!ត្រូវហើយបើសិនណាយើងមិនជឿណាស់ ។

កុសលៈ បាទ!បងគិតថាតុលាការហ្នឹងអាចធ្វើឲ្យប្រទេសយើងល្អជាងមុន ក្នុងពេលអនាគតឬមួយក៏យ៉ាងម៉េច?

លន់ៈ ខ្ញុំជឿថា បើសិនណាជាទៅមុខតុលាការយើងនិងរឹតតែល្អ ។

កុសលៈ ចឹងបងជឿថាតុលាការហ្នឹងមានភាពជាក់លាក់ល្អទេ ធ្វើការកាត់ទោសទៅមានយុត្តិធម៌ជាក់លាក់ដែលអត់និយាយឲ្យត្រង់?

លន់ៈ និយាយឲ្យត្រង់ដែលខ្ញុំធ្លាប់ជួបណាស់ ។

កុសលៈ បាទ ។

លន់ៈ កន្លងទៅមិនទាន់ជាល្អប៉ុន្មានទេ សើច... ។

កុសលៈ ហេតុអីចឹងបង បងជួយប្រាប់ខ្ញុំផងមើល?

លន់ៈ ចុះឯណាបើយើងតាមដានពត៍មានដែរ កំពង់ត្រូវការរើរុះហើយប្រពន្ធ័តុលាការកន្លែងណាត្រូវកន្លែងណាមិនត្រូវដកហូតបញ្ចប់មុខតំណែងអីយ៉ាងម៉េចនោះ ខ្ញុំគិតថារឿងមិនល្អបានដកហូត មានស្អីក្រៅពីពុករលួយ ។

កុសលៈ បាទ!និយាយទៅរឿងពុករលួយ! ចឹងសួរដែលទាក់ទងមួយទៀត ថាតើបងយល់ថា បងគិតមើលទៅក្នុងរបបខ្មែរក្រហម ហេតុអីបានជាយើងមានរបបខ្មែរក្រហមចឹង ហេតុអីបានជាប្រទេសយើងធ្លាក់ដូចថា មានរបបខ្មែរក្រហមចឹង?

លន់ៈ បើយើងគិតឲ្យដល់ទៅក្នុងសម័យនោះណាស់ បើយើងប្រៀបធៀបក្នុងពិភពលោកវាបានប្រែប្រួលធ្វើឲ្យប្រទេសក្នុងរបបរាជ្យជានិយមរបបចាស់ពីដើមមកវាត្រូវការប្រែប្រួលចឹងយើងធ្វើបដិវត្តយើងធ្វើកុម្មុយនីស្តណាស់ តែខ្ញុំក៏បានពិនិត្យឃើញដែលថា បញ្ហាមួយចំនួនខ្ញុំគិតថា របបបីឆ្នាំរបបប៉ុល ពតណាស់ ។

កុសលៈ បាទ ។

លន់ៈ ដែលធ្វើឡើងមកនេះ ខ្ញុំគិតថា មួយចំណែកខាតមួយចំណែកចំនិញ បានថាចំនិញ ។

កុសលៈ ចំនិញយ៉ាងម៉េចបង?

លន់ៈ បើនិយាយមួយផ្នែកខាងនេះណាស់ ។

កុសលៈ បាទ ។

លន់ៈ ចង់និយាយថា ពួកខ្ញុំនៅខាងជាយដែននេះបានស្គាល់ទឹកដីជាយដែនប្រាកដនោះឯងពីព្រំប្រទល់លាវមកទៅលិចទៅ បើសិនណាកុំមានបដិវត្តស្មានថាពួកខ្ញុំបានមកស្គាល់ទឹកដីនៅលើខ្នងភ្នំដងរែក មកពីសម័យបដិវត្តខ្មែរក្រហមហ្នឹងឯង ។

កុសលៈ ពីប្រទេសលាវ?

លន់ៈ បាទ!ពីមុំបីមក ។

កុសលៈ ចឹងរបបហ្នឹងជំនាន់ហ្នឹង វាជៀសវាងមិនបានបើយើងពិនិត្យទៅលើសកម្មភាព?

លន់ៈ បាទ! យើងជៀសមិនបានតែម្តង ។

កុសលៈ ចឹងជៀសមិនរួច?

លន់ៈ បាទ!ជៀសមិនរួចពីសភាពការហ្នឹង គេតម្រូវឲ្យយើងធ្វើចឹងទៅហើយ ។

កុសលៈ ចឹងបងគិតថា ជារឿងអកុសល្យជារឿងអាក្រក់ដែលមានរឿងទាំងអស់ហ្នឹងកើតឡើង តើវាថា ដូចជាវាមានអ្វីកើតឡើងក្នុងរបបបីឆ្នាំហ្នឹង ជារឿងសោកស្តាយ បើសិនជាយើងសម្លឹងមើលទៅអនាគត គួរតែបំភ្លេចចោលពីអតីតកាល?

លន់ៈ បាទ!យើងគួរតែបំភ្លេចចោល ។

កុសលៈ ហេតុអីបង?

លន់ៈ ពីព្រោះថា វាបន្តឲ្យមានការឈឺចាប់ច្រើន តែក៏មានមេរៀនច្រើនណាស់ដែរ ចង់និយាយថា សម្រាប់ឲ្យអ្នកជួបដូចខ្ញុំណាស់ ។

កុសលៈ ហ្នឹងជាមេរៀនមួយល្អ?

លន់ៈ បាទ ។

កុសលៈ មេរៀនហ្នឹងជួយឲ្យយើងយ៉ាងម៉េចខ្លះបង?

លន់ៈ ជួយឲ្យយើងចេះឈឺចាប់ ចំពោះខ្លួនឯង យកការឈឺចាប់ហ្នឹងឲ្យក្លាយទៅជាការភិវឌ្ឍន៍វិញណាស់ ទៅជាបទពិសោធន៍ ទៅជាការលត់ដំខ្លួនឯងហ្នឹងណាស់ ។

កុសលៈ អរគុណច្រើនបង តើអ្វីដែលកើតឡើងជាវិប្បដិសារីយ៍មួយប៉ុន្តែយ៉ាងណា តើបងមានបញ្ហាមិញជារឿងល្អឬមួយជារឿងអាក្រក់?

លន់ៈ មានល្អត្រង់ដែលថា គេបានប្រែប្រួលឲ្យយើងនៅស្រុកអីនោះហើយមកបានស្គាល់តែប៉ុណ្ណឹងទេ ។

កុសលៈ បាទ ។

លន់ៈ គេបានឲ្យយើងនេះ បានលុតដំក្នុងសម័យគេគ្រប់បែបយ៉ាង បានសេចក្តីថា អាអត់ក៏មាន អាឃ្លានក៏មាន អាលំបាកគ្រប់បែបយ៉ាងក៏មាន អាព្រៃភ្នំមិនដែលទៅដល់យើងទៅដល់ ។

កុសលៈ បាទ!ចឹងជាការល្អចុះខាងផ្នែករឿងអកុសលដែលមិនល្អដូចជាការកាប់សម្លាប់អី បងជឿថាវាមានកើតឡើងទេ?

លន់ៈ រឿងដែលជាប់មានវិប្បដិសារីយ៍នេះ ខ្ញុំគិតថាវាជាអកុសល្យត្រង់ថា ប្រទេសយើងសម័យនោះវាមិនបានភាពសុខសាន្តត្រូវមានរបបយ៉ាងព្រៃផ្សៃយុងឃ្នងកាប់សម្លាប់ណាស់ ។

កុសលៈ បាទ ។

លន់ៈ បានជាប់មានវិប្បសារីយ៍ហ្នឹងទៅ ។

កុសលៈ បាទ!ពេលហ្នឹងបងអត់មានដឹងទេ អត់ដឹងថាប្រទេសយើងធ្លាក់កំរិតហ្នឹងអត់ដឹងទេ?

លន់៖ ខ្ញុំមានដឹងអីថា វាដល់ទៅសម្បើមម្ល៉េះមានដឹងណា ។

កុសល៖ ហេតុអីដោយសារថា បងនៅដាច់ខាងនោះមក?

លន់៖ បាទ!កាត់ផ្តាច់អស់ហើយ ដាប់មកខាងកងទ័ពនេះមក ។

កុសល៖ ចឹងបងជឿថា រឿងរ៉ាវកាប់សម្លាប់ហ្នឹងមានកើតមានមែន?

លន់៖ បាទ!ខ្ញុំជឿថា វាអាចកើតមានមែន តែត្រង់ថា សម្រាប់តែខ្មែរក្រហមឬមិនដឹងថាខាងណាខ្ញុំមិនអាចថាបានដែរ ។

កុសល៖ បាទ!អ្នកណាជាអ្នកធ្វើរឿងអស់ហ្នឹងបង?

លន់៖ បើថា សម្រាប់យើងនិយាយខ្លីៗទៅណាស់ ។

កុសល៖ បាទ ។

លន់៖ នោះឯងមិនថាបានទេ តាមមើលពិបាកថា ណាស់ ។

កុសល៖ ថាលើបញ្ជាឬមួយយ៉ាងម៉េច?

លន់៖ ថា ថ្នាក់លើទៅ ព្រោះយើងនៅក្រោម យើងយុវជនមានទៅដឹងអី ។

កុសល៖ បាទ ។

លន់៖ គ្រាន់តែយើងឃើញបញ្ហាខ្លះវា ពិត ។

កុសល៖ ចឹងបងជឿថា តុលាការខ្មែរក្រហមសព្វថ្ងៃវាអាចរកយុត្តិធម៌ចំពោះការផ្សះផ្សារជាតិសម្រាប់ប្រជាជនទូទៅដែលទេ?

លន់៖ ពិបាកកំណត់ណាស់កន្លែងហ្នឹង ។

កុសល៖ ចំពោះការផ្សះផ្សារដដែលក្នុងការអត់ទិនទោសអ្នកជនរងគ្រោះគួតែទប់កំហឹងក្នុងចិត្ត ដូចជាអ្នកជនរងគ្រោះនៅក្នុងសម័យខ្មែរក្រហម ពួកគាត់ថាឈឺចាប់ណាស់ គាត់មានការឈឺចាប់ផ្សេងរបស់គាត់ ហើយដើម្បីផ្សះផ្សារជាតិបងគិតថា ពួកគាត់គួតែរៀនទុកកំហិតក្នុងចិត្តឬក៏យ៉ាងម៉េច?

លន់៖ បើសិននេះគួតែសើច... ។

កុសល៖ គួតែទប់បង?

លន់៖ បាទ ។

កុសល៖ ដល់កំរិតណាដែលពី១ដល់៥ ?

លន់៖ គួតែទប់កំរិតណាដែលយើងទប់បានទៅណាស់ ។

កុសល៖ ចឹងទប់ក្នុងកំរិតល្មមឲ្យវានៅក្នុងកំរិតល្មម?

លន់៖ បាទ ។

កុសលៈ បងតែងនឹកថា បងមិនចង់គិតពីរបបហ្នឹងទៀតទេ?

លន់ៈ ខ្ញុំមិនចឹងគិតទេ គ្រាន់តែប៉ុណ្ណឹងខ្ញុំឆ្អែតណាស់ទៅហើយ ។

កុសលៈ ចឹងគួតែគិតរឿងផ្សេងទៅវិញ?

លន់ៈ បាទ!រឿងផ្សេងរឿងថ្មី ។

កុសលៈ វាជារឿងកន្លងផុតទៅហើយ?

លន់ៈ បាទ!អតីតកាលទៅ ។

កុសលៈ តើបងជឿលើបុណ្យបាបកម្មពារដែលទេ?

លន់ៈ ជឿ ។

កុសលៈ បងដែលនៅមានកំហឹងក្នុងខ្លួនដែលទេ?

លន់ៈ បើសិនជារឿងកំហឹងខ្ញុំមិនសូវមានទេ សព្វថ្ងៃ ។

កុសលៈ ចឹងមានតិច?

លន់ៈ បាទមានតិច ។

កុសលៈ ចឹងកាត់បន្ថយច្រើន?

លន់ៈ បាទ ។

កុសលៈ ចឹងហេតុអីបានជាកាត់បន្ថយបានច្រើន?

លន់ៈ វាបើសម្រាប់ខ្ញុំណាស់ វាកើតមកពីការពិចារណា ហើយម្យ៉ាងទៀតវាចាស់ទៅហើយមិនជាត្រូវខឹងមិនដឹងជាត្រូវគំនុំអីណាណីអត់ទេ ត្រូវតែកាត់បន្ថយកន្លែងណាអធ្យាស្រ័យ ។

កុសលៈ តើបងគិតថា អាចតែបងឆ្លើយហើយក្នុងការអត់ខិនទោសឲ្យគ្នាទៅវិញទៅមក តែការអត់ខិនទោសឲ្យគ្នាទៅវិញទៅមកជាការសំខាន់មួយដល់កំរិតណាក្នុងការផ្សះផ្សារជាតិហ្នឹង?

លន់ៈ វាសំខាន់បំផុតត្រង់ថា គួតែយោគយល់លើកហេតុផលណាដែលគួទទួលយកបាន ។

កុសលៈ ជិតចប់ហើយបងថែមតែប៉ុន្មានសំនួរទៀតហើយ ចឹងបងធ្វើចម្ការដែរ?

លន់ៈ បាទ!ខ្ញុំធ្វើស្រែដែរ ស្ទូង ។

កុសលៈ ចឹងខ្ញុំមើលសំនួរបួនដបទៀតហើយបង ចឹងបងមានតាមដានទៅពេលគេកាត់ទោសឌុចដែលបង?

លន់ៈ ខ្ញុំមិនសូវដែលបានតាមដានទេ និយាយរួមវាទាក់ទងទៅបញ្ហាការកាត់ទោសអី ខ្ញុំមិនសូវជាចាប់អារម្មណ៍ ។

កុសលៈ ចឹងចំពោះឌុចហ្នឹង ថាតើគាត់?

លន់ៈ បើសិនថា ចោទគាត់ជាសត្រូវខ្មាំងក៏ខ្ញុំមិនអាចកំណត់បាន វាធ្វើតាមគេដូចតែគ្នា ។

កុសលៈ	បាទ!ចឹងគាត់គោរពបញ្ជាតាមតែគេ?

លន់ៈ	បើមិនសម្លាប់មិនគោរពទៅតាមបទបញ្ជាគេ គេសម្លាប់ដូចតែគ្នា ។

កុសលៈ	ចុះហេតុអីបានជាគាត់មិនរត់ភាសខ្លួនចេញពីប្រទេស?

លន់ៈ	អាហ្នឹងវាសម្រាប់ទៅលើបុគ្គលហ្នឹង ។

កុសលៈ	តែដោយសារថា បងថាគាត់គោរពបញ្ជាគេ?

លន់ៈ	ហ្នឹងហើយមកពីគោរពហ្នឹងណាស់ ពួកខ្ញុំទេដែលមានឱកាសនៅកន្លែងនេះណាស់ ។

កុសលៈ	ត្រូវហើយវាជិតព្រំដែន?

លន់ៈ	ព្រំដែន មួយចំនួនធ្លាយទៅដល់អាមេរិចមិត្តភិក្ខុសព្វថ្ងៃហ្នឹង ។

កុសលៈ	ចឹងមាននៅអាមេរិចដែរ?

លន់ៈ	សើច...កាលថាខុសវិន័យកាលនោះនិយាយត្រឹមវិន័យទេ តែមិនស្រួលស្ដាប់ហ្នឹង ។

កុសលៈ	ចឹងសរុបសេចក្ដីទៅបងយល់ថា ដួនណាអ៊ីដែលឌុចបានធ្វើជាការត្រឹមត្រូវខុសឬពិបាកយល់ខុសដែលតែវាខុសទៅហ្នឹងការសីលធម៌គុណធម៌ជំទាន់ហ្នឹង?

លន់ៈ	បាទ!សរុបទៅនោះវាខុសហើយ ខុសពីសីលធម៌គុណធម៌ហើយ ខុសមែនទែនណាស់ បើនិយាយពីច្បាប់សិទ្ធិវាខុសពេក ។

កុសលៈ	បាទ ។

លន់ៈ	គោរពគេខ្លាំងពេក ។

កុសលៈ	បើខ្លួនបងវិញ បងហ៊ានប្រឆាំងដែរ?

លន់ៈ	បើសិនណាសម្រាប់ខ្ញុំវិញ ខ្ញុំអាចហ៊ានប្រឆាំង កុំថាខ្ញុំធំដល់នោះ នៅជាយដែននេះកាលខ្ញុំរត់ទៅថៃតិចណាស់កាលសម័យនោះ ។

កុសលៈ	ចឹងបងយល់ពីសកម្មភាពរបស់ឌុច អ៊ីដែលឌុចធ្វើនោះមានភាពត្រឹមត្រូវទេ បើមនុស្សដែលគេបញ្ជាឲ្យសម្លាប់នោះជាសត្រូវរបស់រដ្ឋ?

លន់ៈ	ខ្ញុំគិតថា បើសិនជាសត្រូវរបស់ជាតិ ខ្ញុំគិតថាវាមិនមែនជារឿងខុសអីទេ ។

កុសលៈ	បាទ!អ្នកហ្នឹងប្រព្រឹត្តិប្រឆាំងនិងអគ្គការ ដូចជាការលួចអីជាដើម លួចទ្រព្យសម្បត្តិ?

លន់ៈ	អានោះដូចជាមិនមានអីទេ ។

កុសលៈ	មិនត្រឹមត្រូវ?

លន់ៈ	បាទ!ព្រោះយើងទាក់ទងតែរឿងពួកក្បត់ជាតិឬក៏អ្នកប្រឆាំងនិងជាតិ ។

កុសលៈ	បាទ ។

លន់ៈ	បើថា ត្រឹមលួច ។

កុសលៈ	លួចអីអត់ទេ?

លន់ៈ	បាទ ៗ

កុសលៈ	ចឹងបើគេជាភ្នាក់ងារសម្ងាត់«កា-សេ-បេឬសេ-អ៊ី-អា អីចឹងជាដើម?

លន់ៈ	អាហ្នឹងវាសុទ្ធតែរឿងនយោបាយរបស់គេ ៗ

កុសលៈ	ចឹងបើសិនជាសត្រូវរបស់វណ្ណៈ ដូចថាពួកនាយទន់ពួកលន់ នល់ពួកអី?

លន់ៈ	អាហ្នឹងជារឿងខ្មែរគ្នាឯង ៗ

កុសលៈ	ចឹងអ្នកដែលទទួលបញ្ជានិយាយពីឌុច?

លន់ៈ	បាទ ៗ

កុសលៈ	អ្នកដែលទទួលបញ្ជាធ្វើទារុណកម្មនោះបានប្រព្រឹត្តិអំពើដែលត្រឹមត្រូវអំពើដែលគាត់ធ្វើនោះជារឿងត្រឹមត្រូវ បើសិនបើឌុចហ្នឹងទទួលបញ្ជាពីគេ បើមិនធ្វើទេ គេសម្លាប់គាត់ឬគ្រួសារគាត់?

លន់ៈ	បាទ ៗ

កុសលៈ	បើសិនជាគ្រួសារគាត់មិនត្រូវមានគ្រោះថ្នាក់ តើជាការត្រឹមត្រូវទេ បើសិនថា គាត់មិនធ្វើចឹងទេ?

លន់ៈ	ត្រូវហើយ ៗ

កុសលៈ	ចឹងបើសិនជាគាត់មិនធ្វើទេ គាត់មិនត្រូវបានចាត់ទុកថា ជាអ្នកបដិវត្តល្អម្នាក់ តែគួតែធ្វើដូចថាឌុចណាស់ បើសិនជាគេបញ្ជាឲ្យសម្លាប់ តើគាត់ចង់ធ្វើជាជនបដិវត្តម្នាក់ឬមួយយ៉ាងណា?

លន់ៈ	អាហ្នឹងវាទាក់ទងទៅហ្នឹង វាមិនអាចបែងចែកបានទេ ពីព្រោះថា បញ្ហាខ្លះយើងអ្នកខាងក្រៅហើយចេះតែថា រឿងគេសើច... ៗ

កុសលៈ	អាហ្នឹងតាមបងយល់ណាស់?

លន់ៈ	តែសម្រាប់ខ្ញុំវិញ ខ្ញុំមិនអាចធ្វើទៅកើតទេកន្លែងណាខ្លះ ៗ

កុសលៈ	បាទ!តែក្រែងលោគាត់ចង់បានជាជនបដិវត្តដ៏ល្អម្នាក់ យើងត្រូវតែធ្វើតាមបញ្ជា?

លន់ៈ	ឬក៏គេអាចកំណត់ថា គេនោះជាមនុស្សអស្ចារ្យក្នុងជនបដិវត្តណាស់ ក៏មិនដឹងអត់ដឹង ៗ

កុសលៈ	ចឹងបើមិនធ្វើទេ គេមិនចាត់ទុកថា ជាជនស្នេហាជាតិស្មោះត្រង់ចំពោះអង្គការ តើបងមានតិចឬច្រើន?

លន់ៈ	ពិបាកនិយាយណាស់ ចំពោះបញ្ហាហ្នឹងទាក់ទងរឿងគេនេះឯង ៗ

កុសលៈ ចឹងពី១ដល់៩នេះ បើសិនជាគាត់ហ្នឹង បើគាត់ថា ចំពោះគាត់មិនអាចទទួលខុសត្រូវបានទេ ចំពោះឌុច?

លន់ៈ បាទ ។

កុសលៈ គាត់មិនអាចទទួលខុសត្រូវបានទេ ចំពោះអ្វីដែលគាត់បានធ្វើ ពីព្រោះថា គាត់មិនបានដឹង តើបងយល់ថា ជារឿងត្រឹមត្រូវដល់កំរិតណា ឌុចហ្នឹងថ្នាក់កណ្ដាលដែលគាត់ថា គាត់មិនដឹង គាត់មិនអាចទទួលខុសត្រូវបាន?

លន់ៈ ខ្ញុំគិតថា គាត់ដឹង បានថា គាត់ដឹងព្រោះថាមនុស្សយើងមានបាបមានកម្មជារឿងធម្មតា ។

កុសលៈ បាទ ។

លន់ៈ កម្មកើតចេញអំពើ បើអ្នកប្រព្រឹត្តល្អម៉េចទទួលបានថាល្អទៅ បើប្រព្រឹត្តិអាក្រក់វា អាក្រក់ទៅនោះហើយ យើងទៅបំភ្លៃការពិតយ៉ាងម៉េចបើយើងធ្វើទៅហើយ តាមមើលសមល្មមនិងគាត់ទទួលទៅ ។

កុសលៈ បាទ! ចឹងមនុស្សមិនអាចទទួលខុសត្រូវអ្វីដែលខ្លួនបានធ្វើបានដឹងទេ ប៉ុន្តែមិនបានប្រព្រឹត្តិនោះទេ មានន័យថាគ្រាន់តែដឹងយើងមិនបានធ្វើ យើងមានអីត្រូវទទួលកំហុសទេ?

លន់ៈ នោះឯង ។

កុសលៈ ចឹងមនុស្សម្នាក់មិនអាចទទួលខុសត្រូវចំពោះអ្វីដែលខ្លួនបាន គ្រាន់តែធ្វើតាមបញ្ជារបស់គេនោះទេ ត្រឹមត្រូវណាស់បង?

លន់ៈ បាទ ។

កុសលៈ អ្វីដែលឌុចបានធ្វើក្នុងជំនាន់នោះ គឺជាការត្រឹមត្រូវយល់ស្របយ៉ាងខ្លាំងយល់ស្របសមហេតុផលខ្ញុំមិនយល់ស្របទេ ខ្ញុំមិនយល់ស្របដាច់ខាត ខ្ញុំមិនដឹងដែលតើចម្លើយហ្នឹងចម្លើយមួយណាត្រូវបង ។

លន់ៈ អរ!ឌុចបានធ្វើ?

កុសលៈ អ្វីដែលឌុចបានធ្វើជំនាន់នោះ គឺជាការត្រឹមត្រូវ បងឯកភាពឬក៏យល់ស្របឬមិនយល់ស្រប ឬថាសមហេតុផល មិនចេះនិយាយទេ?

លន់ៈ អត់ទាន់ទេ តែបើថាសម្រាប់ខ្ញុំ ខ្ញុំថាមិនត្រឹមត្រូវទេ សម្រាប់ថាទង្វើរបស់ឌុចហ្នឹង តែគេយល់ថាជាការត្រឹមត្រូវរបស់គេហើយតាមមើល ។

កុសលៈ ចឹងចំពោះគាត់គិតថា ជាការត្រឹមត្រូវ ។

លន់ៈ បាទ ។

កុសលៈ អ្វីដែលគាត់បានធ្វើហ្នឹងវាខុសហើយ ប៉ុន្តែវាពិបាកក្នុងការស្វែងយល់ពីកាលៈទេសៈពេលនោះ?

លន់ៈ ត្រូវហើយ នៅក្នុងសភាពពេលនោះសម័យនោះរបបនោះ ។

កុសលៈ បាទ!វាជាការខុសហើយប៉ុន្តែវាជាការសមហេតុផល ព្រោះអង្គការជំនាន់នោះតម្រូវឲ្យគាត់ធ្វើចឹង?

លន់ៈ បាទ ។

កុសលៈ អ្វីដែលគាត់ធ្វើហ្នឹងវាខុសហើយ ព្រោះវារំលោភទៅលើគោលការណ៍សីលធម៌ ទោះបីជាថ្នាក់លើដាក់បញ្ជាក៏ដោយតែវារំលោភលើសីលធម៌?

លន់ៈ បាទ ។

កុសលៈ ច្រើនទេបង?

លន់ៈ ច្រើន ។

កុសលៈ តើការផ្តន្ទាទោសរបស់ឌុចហ្នឹង បងយល់ថាមានយុត្តិធម៌ដែលទេ គេដាក់៣៥ឆ្នាំ គេបន្ថយដល់១៩ឆ្នាំ បងយល់ថាមានផ្តល់យុត្តិធម៌ទេចឹង?

លន់ៈ ដាក់ប៉ុន្មាន?

កុសលៈ ១៩ឆ្នាំ ។

លន់ៈ ចឹង៣០មក១៩ វាត្រឹមត្រូវល្អហើយ ព្រោះថាអ្នកទទួលត្រូវតែទទួលចឹង កុំឲ្យពួកក្រោយៗកុំឲ្យយកគំរូបតាម ។

កុសលៈ ចឹងអ្នកដែលធ្វើខុសជំនាន់ហ្នឹង គឺថាថ្នាក់លើដាក់បញ្ជាគឺថាយើងមានតែថ្នាក់ដឹកនាំកំពូលទេដែលគួរតែនាំមកកាត់ទោសបង បងនិយាយឆ្លើយលើកមុនហើយណាស់ ។

លន់ៈ បាទ ។

កុសលៈ ចឹងបងចង់បញ្ចប់ត្រឹម០០២ហ្នឹងបានហើយ?

លន់ៈ នោះហើយ ។

កុសលៈ វាសមរម្យហើយ?

លន់ៈ បាទ ។

កុសលៈ ចឹងបងគិតថា គេកាត់ទោសបួននាក់០០២ហ្នឹងគួរតែថា កាត់ទោសគាត់បែបណាដែរ?

លន់ៈ កន្លែងហ្នឹងខ្ញុំអត់យល់ណាស់ ។

កុសលៈ បាទ ។

លន់ៈ មិនដឹងថាត្រូវកាត់យ៉ាងម៉េច អីយ៉ាងណាខ្ញុំអត់យល់ទេ ។

កុសលៈ ចឹងតុលាការហ្នឹងអាចផ្តល់ដូចជាទោសកុំហុសកំរិតធ្ងន់តិចយ៉ាងណា បងគិតមើល គាត់ហ្នឹងមានកំហុសធ្ងន់ប៉ុណ្ណាដែរ?

លន់ៈ សម្រាប់ខ្ញុំណាស់ ខ្ញុំគិតថា ពិបាកនិយាយណាស់ តែថាវាទាក់ទងទៅហេតុផលរបស់គាត់ទៅចុះ ។

កុសលៈ បាទ!ចឹងមានហេតុផលរបស់គាត់?

លន់ៈ បាទ ។

កុសលៈ គាត់ចាស់ៗហើយ?

លន់ៈ គាត់ចាស់ហើយឲ្យមានហេតុផលរបស់គាត់ទៅ ។

កុសលៈ បាទ!ដូចជាអស់ហើយបង អស់ហើយខ្ញុំមានតែសំនួរមួយទៀតទាក់ទងនិងប៉ុល ពត ដែលគាត់ស្លាប់ទៅហើយ តើប៉ុល ពត ហ្នឹង គួតែទទួលខុសត្រូវដល់កំរិតណាដែរ នៅក្នុងរូបភាពមហន្តរាយណ៍នេះ ព្រោះជាគាត់ជាមេដឹកនាំធំបំផុត?

លន់ៈ បាទ!គាត់អ្នកលើគេ បើគាត់នៅរស់គាត់គួតែទទួលម្នាក់ឯងតែម្តង ។

កុសលៈ បាទ ។

លន់ៈ នោះហើយតែគាត់ស្លាប់ទៅយើងមិនដឹងជាម៉េចទៅចុះ បើនៅរស់គួតែគាត់អ្នកទទួលម្នាក់ឯង ។

កុសលៈ ចឹងដល់ទីបញ្ចប់ហើយតើបងមានអីបន្ថែមទៀតទេ ប្រាប់ឲ្យខ្ញុំដឹងបន្ថែម តែសំនួរចុងក្រោយមួយទៀត ខ្ញុំសួរជាប្រយោលទូទៅ តើយើងត្រូវធ្វើអ្វីទៀតដើម្បីឲ្យប្រជាជនយើងមានការផ្សះផ្សារឬអភិវឌ្ឍន៍ទៅមុខទៀត តើរដ្ឋាភិបាលយើងគួតែធ្វើអ្វីខ្លះ អាជ្ញាធរក្នុងស្រុកយើងគួតែធ្វើអ្វីខ្លះ ដើម្បីឲ្យមានការអភិវឌ្ឍន៍និងភាពសុខសប្បាយ ដូចថាមានសន្តិភាពជារៀងរហូត កុំឲ្យមានការប្រេះឆាតទៅទៀតនៅក្នុងស្រុកភូមិយើង តាមយោបល់បងផ្ទាល់បងមានបទពិសោធន៍ យើងត្រូវធ្វើអ្វីទៀត យើងគិតថា តុលាការហ្នឹងវាមិនគ្រប់គ្រាន់ទេ វាមិនចឹង ដូចបងថាចឹង ចឹងបងគិតថា មានអ្វីទៀតដើម្បីឲ្យមានការផ្សះផ្សារជាតិ?

លន់ៈ សម្រាប់ខ្ញុំគិតឲ្យកម្ពុជាយើងមានសន្តិភាពនិងផ្សះផ្សារ ខ្ញុំគិតថាមិនឲ្យមានបន្តទៀត ទី២ទៀតធ្វើយ៉ាងម៉េចឲ្យកម្ពុជាយើងនេះអាចទៅជានិតិរដ្ឋល្អ នេះបើសិនជាការប៉ងប្រាថ្នារបស់ខ្ញុំណាស់ ។

កុសលៈ បាទ!ចឹងទាក់ទងនិងប្រវត្តិសាស្ត្រ តើយើងគួតែបង្រៀនកូនចៅយើងបែបណាដែរ?

លន់ៈ ទាក់ទងរឿងប្រវត្តិសាស្ត្រ?

កុសលៈ បាទ! យើងគួតែអប់រំកូនចៅយើងក៏រិតណាឬយើងគួតែបំភ្លិចចោលឲ្យអស់ អ្វីដែលអាក្រក់ពីមុនមក?

លន់ៈ បើសិនណាយើងលុបបំបាត់អស់ទៅ ក៏មិនបានដែរ ត្រូវយកមកជាមេរៀនខ្លះ ។

កុសលៈ ចឹងយើងត្រូវដកស្រង់ចេញមកជាមេរៀនខ្លះ?

លន់ៈ បាទ!ពីព្រោះថាអ្វីដែលបានឆ្លងកាត់ ។

កុសលៈ ចឹងអប់រំដល់កូនចៅជំនាន់ក្រោយ?

លន់ៈ បាទ ។

កុសលៈ បាទ!ចឹងអរគុណច្រើនមែនទែន បាទចប់ អរគុណបងណាស់ ។

លន់ៈ បាទ ។

**ចប់**